# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានកៅស៊ូ**

General Directorate of Rubber

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅ
# អនុវត្តការងារឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកៅស៊ូ



# មាតិកា


**១. សេចក្តីផ្តើម** ..................... **១**

១.១ ប្រវត្តិកៅស៊ូធម្មជាតិ ..................... ១

១.២ ផលប្រយោជន៍កៅស៊ូធម្មជាតិ ..................... ២

១.៣ ស្ថានភាពកៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ២០១៧ ..................... ២

១.៤ សេណារីយោកៅស៊ូធម្មជាតិឆ្នាំ២០១៨ ..................... ៣

**២. លទ្ធផលការងារសំខាន់ៗ ក្នុងឆ្នាំ២០១៧** ..................... **៤**

២.១ ការងាររដ្ឋបាលនិងនីតិកម្ម ..................... ៤

២.១.១ ការងាររដ្ឋបាលនិងបុគ្គលិក ..................... ៤

២.១.២ ការងារនីតិកម្ម ..................... ៦

២.១.៣ ការងារផ្សព្វផ្សាយ បណ្តុះបណ្តាល និងសិក្ខាសាលា ..................... ៦

២.២ ការងារផែនការនិងហិរញ្ញវត្ថុ ..................... ៨

២.២.១ ការងារផែនការ ..................... ៨

២.២.២ ការងារហិរញ្ញវត្ថុ ..................... ១០

២.៣ ការងារអភិវឌ្ឍន៍ ..................... ១១

២.៣.១ ស្ថិតិផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ ..................... ១១

២.៣.២ ស្ថិតិរោងចក្រ និងសិប្បកម្មកែច្នៃផលិតផលកៅស៊ូធម្មជាតិ ..................... ១៤

២.៤ ការងារពិសោធន៍និងស្រាវជ្រាវ ..................... ១៥

២.៥ ការងារសហប្រតិបត្តិការអន្តរជាតិ ..................... ១៧

២.៥.១ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) ..................... ១៧

២.៥.២ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB) ..................... ១៩

២.៥.៣ កិច្ចសហប្រតិបត្តិការជាមួយ CIRAD ..................... ១៩

២.៥.៤ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ..................... ២០

២.៥.៥ កិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន ..................... ២០

២.៥.៦ កិច្ចសហប្រតិបត្តិការជាមួយCATAS ..................... ២០

២.៥.៧ ការរៀបចំគម្រោងអភិវឌ្ឍន៍កៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ និងវៀតណាម (CLV-DTA) ..................... ២១

**៣. បញ្ហាប្រឈម** ..................... **២១**

**៤. សំណូមពរ** ..................... **២១**

**៥. សន្និដ្ឋាន** ..................... **២២**

**៦. ទិសដៅអនុវត្តការងារឆ្នាំ២០១៨** ..................... **២២**

# តារាង


តារាងទី១ មន្ត្រីរាជការតាមកម្រិតជំនាញ ..... ៥
តារាងទី២ ស្ថិតិផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៧ (ហិកតា) ..... ១២
តារាងទី៣ កម្មវិធីសន្និសីទ កិច្ចប្រជុំ និងសន្និបាតប្រចាំឆ្នាំ២០១៧ របស់ ANRPC ..... ១៨
តារាងទី៤ ព្រឹត្តិការណ៍សំខាន់របស់ ANRPC ក្នុងឆ្នាំ២០១៨ ..... ១៩


# ដ្យាក្រាម


ដ្យាក្រាមទី១ ការប្រៀបធៀបថវិកាអនុម័តឆ្នាំ២០១៦ និង២០១៧ ..... ១០
ដ្យាក្រាមទី២ ការប្រៀបធៀបថវិកាអនុវត្តនិងថវិកាអនុម័តឆ្នាំពី២០១០-២០១៧ ..... ១១
ដ្យាក្រាមទី៣ អត្រាភាគរយនៃប្រភេទផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០១៧(ហិកតា) ..... ១២
ដ្យាក្រាមទី៤ ទំហំប្រភេទផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៣-២០១៧ (ហិកតា) ..... ១២
ដ្យាក្រាមទី៥ ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុប ឆ្នាំ២០១៣-២០១៧(ហិកតា) ..... ១៣
ដ្យាក្រាមទី៦ ផលិតកម្មនិងការនាំចេញកៅស៊ូធម្មជាតិឆ្នាំ២០១៣-២០១៧ ..... ១៤
ដ្យាក្រាមទី៧ ចំនួនរោងចក្រ សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូ២០១៣-២០១៧ ..... ១៥
ដ្យាក្រាមទី៨ អត្រាគុណភាពផលិតផលកៅស៊ូ២០១៣-២០១៧ ..... ១៥


# ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១ រចនាសម្ព័ន្ធអគ្គនាយកដ្ឋានកៅស៊ូ ..... ២៤
ឧបសម្ព័ន្ធទី២ លទ្ធផលនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធី ..... ២៥
ឧបសម្ព័ន្ធទី៣ គោលដៅនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៨ ..... ២៩
ឧបសម្ព័ន្ធទី៤ ស្ថិតិ ផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិឆ្នាំ១៩៨០-២០១៧ ..... ៣២
ឧបសម្ព័ន្ធទី៥ ស្ថានភាពការងារអាជីវកម្ម ផលិតកម្ម និងនីហរ័ណកម្មកៅស៊ូឆ្នាំ២០១៧ ..... ៣៣
ឧបសម្ព័ន្ធទី៦ ស្ថិតិផ្ទៃដីដំណាំកៅស៊ូកម្ពុជាឆ្នាំ២០១៧ ..... ៣៤
ឧបសម្ព័ន្ធទី៧ ស្ថិតិផ្ទៃដីអតីតចម្ការកៅស៊ូរដ្ឋ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា(វសកក)ឆ្នាំ២០១៧ ..... ៤០
ឧបសម្ព័ន្ធទី៨ ស្ថិតិចម្ការកៅស៊ូលើសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០១៧ ..... ៤១
ឧបសម្ព័ន្ធទី៩ ស្ថិតិផ្ទៃដីកៅស៊ូគ្រួសារឆ្នាំ២០១៧ ..... ៤៦
ឧបសម្ព័ន្ធទី១០ ស្ថិតិផ្ទៃដីកៅស៊ូលម្អិតតាមខេត្តឆ្នាំ២០១៧ ..... ៤៧
ឧបសម្ព័ន្ធទី១១ តារាងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលម្ចាស់វិនិយោគក្នុងស្រុក និងបរទេសលើដំណាំកៅស៊ូឆ្នាំ២០១៧ ..... ៥៤
ឧបសម្ព័ន្ធទី១២ តារាងលម្អិតរោងចក្រ-សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូ ប្រចាំឆ្នាំ២០១៧ ..... ៥៥
ឧបសម្ព័ន្ធទី១៣ ស្ថិតិផលិតផល និងការនាំចេញកៅស៊ូធម្មជាតិពីឆ្នាំ២០០៧-២០១៧ ..... ៥៦
ឧបសម្ព័ន្ធទី១៤ ស្ថិតិផ្ទៃដីកៅស៊ូធម្មជាតិពីឆ្នាំ២០០៧-២០១៧ ..... ៥៧
ឧបសម្ព័ន្ធទី១៥ ចំណូលថវិការដ្ឋឆ្នាំ២០១៧ ..... ៥៨

# បទបង្ហាញ

លទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកៅស៊ូ ........ ៥៩

# រូបថត

រូបថតស្តីពីសកម្មភាពថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ ........ ៦៩
រូបថតស្តីពីសកម្មភាពនាយកដ្ឋានរដ្ឋបាល និងនីតិកម្ម ........ ៧១
រូបថតស្តីពីសកម្មភាពនាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ ........ ៧២
រូបថតស្តីពីសកម្មភាពនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ ........ ៧៣
រូបថតស្តីពីសកម្មភាពនាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ ........ ៧៤
រូបថតស្តីពីសកម្មភាពនាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ ........ ៧៥
រូបថតស្តីពីសកម្មភាពវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ........ ៧៦

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅអនុវត្តការងារ ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកៅស៊ូ

## ១. សេចក្តីផ្តើម

### ១.១ ប្រវត្តិកៅស៊ូធម្មជាតិ

១- ដំណាំកៅស៊ូត្រូវបានដាំជាលើកដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជានាឆ្នាំ១៩១០ ដោយលោក **ប៊ូ យ៉ា** ជនជាតិបារាំង នៅក្នុងស្រុកព្រៃនប់ ខេត្តកំពត (បច្ចុប្បន្ន ខេត្តព្រះសីហនុ) លើផ្ទៃដីជាង១៥០ហិកតា។ ដល់ឆ្នាំ១៩២១ ទើបដំណាំកៅស៊ូជាលក្ខណៈឧស្សាហកម្មទ្រង់ទ្រាយធំ ត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនវិនិយោគរបស់បារាំងធំៗចំនួន៥ នៅលើដីក្រហមបាសាល់នៅខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តរតនគិរី លើផ្ទៃដីទំហំជាង៥០.០០០ហិកតា។ រហូតមកដល់ឆ្នាំ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាបានពង្រីកផ្ទៃដីជាង៦៤.០០០ហិកតា ក្នុងនោះផ្ទៃដីចៀរជ័រមានជាង៣៩.០០០ហិកតា ដោយទទួលបានផលិតផលកៅស៊ូបានជាង៥០.០០០តោន សម្រាប់ការប្រើប្រាស់នៅក្នុងស្រុកនិងការនាំចេញទៅបរទេស។ នៅជំនាន់នោះកម្ពុជាត្រូវបានអន្តរជាតិទទួលស្គាល់ច្បាស់ថាជាប្រទេសដែលមានចម្ការកៅស៊ូល្អ ដែលមានទិន្នផលនិងផលិតផលកៅស៊ូប្រកបដោយគុណភាពខ្ពស់នៅក្នុងតំបន់អាស៊ី។

២- ចាប់តាំងពីឆ្នាំ១៩៧០មក ដោយសារសង្គ្រាមក្នុងស្រុក ជាពិសេសដំណាក់កាលចុងក្រោយស្ថិតក្រោមរបបគ្រប់គ្រងរបស់ពួកខ្មែរក្រហម រាល់ហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យស្ទើរដល់ឫសគល់ រហូតដល់អាយុជីវិតប្រជាជនរាប់លាននាក់ត្រូវបានទទួលរងគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ និងស្ថានភាពចម្ការកៅស៊ូក៏ដូចជាជីវិតកម្មកររាប់ពាន់នាក់ត្រូវទទួលរងគ្រោះថ្នាក់ និងចម្ការកៅស៊ូខូចខាតយ៉ាងធ្ងន់ធ្ងរ។

៣- ចាប់ពីឆ្នាំ១៩៨០ រដ្ឋាភិបាលបានរៀបចំដាក់ឱ្យដំណើរការស្តារ និងធ្វើអាជីវកម្មចម្ការកៅស៊ូចាស់ៗដែលនៅសេសសល់ឡើងវិញ រហូតមកដល់បច្ចុប្បន្ននិងបានដាក់ចេញនូវសេចក្តីប្រកាសស្តីពីការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារនៅកម្ពុជា ព្រមទាំងបានផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់ដំណាំកៅស៊ូដល់វិនិយោគិនក្នុងស្រុកនិងបរទេស ក្នុងគោលបំណងប្រែក្លាយកម្ពុជា ទៅជាប្រទេសផលិតករកៅស៊ូដ៏មានសក្តានុពលនៅក្នុងតំបន់ និងជាប្រទេសផ្គត់ផ្គង់ផលិតផលកៅស៊ូមួយចំណែកចូលទៅក្នុងទីផ្សារពិភពលោក។ រហូតមកដល់បច្ចុប្បន្ននេះ ដំណាំកៅស៊ូនៅតែត្រូវបានគេប្រសិទ្ធនាមថាជា " **មាសស** " និងត្រូវបានរាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់ខ្ពស់បន្ទាប់ពីផលិតកម្មស្រូវ។ ជាពិសេសចាប់តាំងពីឆ្នាំ១៩៩៣ បន្ទាប់ពីរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់អតីតចម្ការកៅស៊ូរដ្ឋទាំង៧ ជាបន្តបន្ទាប់ពីស្វ័យាភិបាលសេដ្ឋកិច្ច មកជាសហគ្រាសសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និងចុងក្រោយបានធ្វើអវិនិយោគឱ្យទៅផ្នែកឯកជនគ្រប់គ្រងទាំងស្រុងក្នុងអំឡុងឆ្នាំ២០០៨-២០០៩។ ទន្ទឹមនឹងការធ្វើឯកជនភាវូបនីយកម្មអតីតចម្ការកៅស៊ូរដ្ឋ តម្លៃកៅស៊ូបានកើនឡើងខ្ពស់ជាបន្តបន្ទាប់ និងស្របពេលដែលរាជរដ្ឋាភិបាលបានផ្តល់សម្បទានដីសេដ្ឋកិច្ចដល់វិនិយោគិនក្នុងស្រុកនិងបរទេស ជាកត្តាជំរុញឱ្យឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាទាំងចម្ការកសិឧស្សាហកម្ម និងចម្ការកៅស៊ូគ្រួសារបានចាប់ផ្តើមបង្កើនសន្ទុះនិងមានការវិវឌ្ឍមួយប្រកបដោយថាមភាពទាំងនៅក្នុងផ្នែកដាំដុះ ការយកផល និងការនាំចេញផលិតផលកៅស៊ូផងដែរ។

## ១.២ ផលប្រយោជន៍កៅស៊ូធម្មជាតិ

៤- កៅស៊ូធម្មជាតិ គឺជាដំណាំយុទ្ធសាស្ត្រនិងសេដ្ឋកិច្ចមួយប្រភេទដែលផ្តល់ប្រយោជន៍ជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ ដល់សង្គមទាំងមូល និងបរិស្ថាន ជាពិសេសបានចូលរួមលើកកម្ពស់ប្រាក់ចំណូលសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារកសិករ ចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារនិងមុខរបរមានស្ថិរភាពជូនប្រជាពលរដ្ឋនៅតាមតំបន់ជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុក ផ្តល់ជាវត្ថុធាតុដើមសម្រាប់វិស័យឧស្សាហកម្ម ផលិតជាមុខទំនិញរាប់ពាន់មុខសម្រាប់បម្រើតម្រូវការប្រើប្រាស់ប្រចាំថ្ងៃដូចជា៖ សំបកកង់យានយន្ត សម្ភារក្នុងលំនៅដ្ឋាន ក្នុងផ្នែកវេជ្ជសាស្ត្រ (ស្រោមដៃពេទ្យ ស្រោមអនាម័យ។ល។) និងប្រើជាកំណល់សំណង់អាគារ ផ្លូវថ្នល់ និងស្ពានធំៗ ទប់ទល់ការជួលរលំដោយសាររញ្ជួយផែនដី។ល។ ផ្តល់ឈើសម្រាប់ប្រើប្រាស់សំណង់ ផលិតគ្រឿងសង្ហារឹម ជាឈើឥន្ធនៈ ចូលរួមចំណែកជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើធម្មជាតិ ការពារការហូរច្រោះដី និងជាគម្របបៃតងឡើងវិញដើម្បីចូលរួមក្នុងការថែរក្សាលំនឹងបរិស្ថាន ដោយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុដែលជាបញ្ហាពិភពលោកសំខាន់មួយក្នុងពេលបច្ចុប្បន្ន។

## ១.៣ ស្ថានភាពកៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ២០១៧

៥- តម្លៃកៅស៊ូធម្មជាតិបានចាប់ផ្តើមងើបឡើងបន្តិចចាប់ពីចុងឆ្នាំ២០១៦ មកដល់ពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៧ អាស្រ័យដោយតម្លៃមុខទំនិញលើទីផ្សារអន្តរជាតិ តម្លៃប្រេងឆៅមានភាពល្អប្រសើរ និងកំណើនតម្រូវការដ៏រហ័សនៃឧស្សាហកម្មកម្មន្តសាល ដូចជាការផលិតសំបកកង់រថយន្តធុនធ្ងន់។ ក្រោយមកប្រទេសថៃជាប្រទេសផលិតចម្បង បានបញ្ចេញឃ្លាំងស្តុករបស់ខ្លួនបួនដងជាប់ៗគ្នា ដែលនាំឱ្យមានការផ្គត់ផ្គង់ឆាប់រហ័ស។ ទោះជាយ៉ាងណាក៏ដោយ កំណើននៃការប្រើប្រាស់មិនបានផ្លាស់ប្តូរទេ ដូច្នេះតម្លៃកៅស៊ូធម្មជាតិបានធ្លាក់ចុះចាប់ពីចុងខែកុម្ភៈដល់ចុងខែមិថុនា ប៉ុន្តែបានកើនឡើងវិញបន្តិចកាលពីខែកក្កដា ឆ្នាំ២០១៧ ហើយតម្លៃកៅស៊ូធម្មជាតិនឹងកើនឡើងបន្តិច អាស្រ័យដោយទីផ្សារបើកទូលាយ និងការផ្គត់ផ្គង់ថយចុះនៅឆ្នាំក្រោយ។

៦- ក្នុងឆ្នាំ២០១៧ ផលិតកម្មកៅស៊ូធម្មជាតិពិភពលោកបានកើនឡើង៦,៨% ស្មើនឹង១៣,៣លានតោន ធៀបនឹងឆ្នាំ២០១៦ មានបរិមាណ១២,៤លានតោន ដែលការផ្គត់ផ្គង់កៅស៊ូធម្មជាតិពិភពលោករបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) ប្រមាណ៩០% ។ ទន្ទឹមនឹងការប្រើប្រាស់កៅស៊ូធម្មជាតិលើពិភពលោកបានកើនឡើងក្នុងកម្រិត១,៤% ស្មើនឹង១២,៩លានតោន ដែលជាសញ្ញាធ្វើឱ្យតម្លៃកៅស៊ូធម្មជាតិល្អប្រសើរដោយទាក់ទងទៅនឹងតម្លៃប្រេងខ្ពស់ជាងមុន និងការកាត់បន្ថយនូវការផ្គត់ផ្គង់ដែលបានព្រមព្រៀងលើកមុនដោយប្រទេសផលិតកៅស៊ូធម្មជាតិដ៏ធំទាំងបី (ប្រទេសថៃ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី)។

៧- ដោយមានការខិតខំដោះស្រាយតម្លៃកៅស៊ូធម្មជាតិធ្លាក់ចុះ ប្រទេសថៃ ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ដែលជាប្រទេសសមាជិកនៃក្រុមប្រឹក្សាត្រីភាគីអន្តរជាតិ (International Tripartite Rubber Council: ITRC) បានព្រមព្រៀងកាលពីចុងខែវិច្ឆិកា ឆ្នាំ២០១៧ ដើម្បីកាត់បន្ថយបរិមាណនាំចេញកៅស៊ូធម្មជាតិ៣៥០.០០០តោន ចាប់ពីសប្តាហ៍ទី៤ ខែធ្នូ ឆ្នាំ២០១៧ រហូតដល់បំណាច់ខែមីនា ឆ្នាំ២០១៨ និងបានដាក់ចេញនូវវិធានការដទៃទៀតក្នុងការផ្តល់កម្ចីឧបត្ថម្ភធន ដើម្បីលើកទឹកចិត្តដល់ការដាំដុះនិងបង្កើនផលិតភាព។

៨- តាមការលើកឡើងដោយអាជ្ញាធរកៅស៊ូថៃ គ្រោះទឹកជំនន់ជាច្រើនសប្តាហ៍បានបង្កជាឧបសគ្គកម្រិតខ្ពស់ដល់ការចៀរជ័រកៅស៊ូប្រមាណ២/៣ នៅតំបន់ដាំដុះកៅស៊ូភាគខាងត្បូងនៃប្រទេសថៃដែលនាំចេញកៅស៊ូធម្មជាតិ

ធំបំផុតរបស់ពិភពលោក ប្រមាណ៤០% នៃការផ្គត់ផ្គង់កៅស៊ូធម្មជាតិពិភពលោក។ ផលិតផលកៅស៊ូថៃត្រូវបានគេរំពឹងថានឹងធ្លាក់ចុះ៧,៦%នៅឆ្នាំ២០១៧ មកនៅត្រឹម៤,៣៨លានតោន គឺធ្លាក់ចុះពីចំនួន៤,៧៤លានតោន ដែលគេរំពឹងទុកកាលពីមុន។

## ១.៤ សេណារីយោកៅស៊ូធម្មជាតិឆ្នាំ២០១៨

៩- យោងតាមការព្យាករណ៍របស់ International Monetary Fund IMF Scenario (IMF) តម្រូវការកៅស៊ូធម្មជាតិលើពិភពលោក នឹងកើនឡើងប្រមាណ៣,៥% ស្មើនឹង១៣,០៣លានតោន ក្នុងឆ្នាំ២០១៧ និង២,៤% ស្មើនឹង១៣,៣៤លានតោន ក្នុងឆ្នាំ២០១៨។ ដោយឡែក ការព្យាករណ៍របស់ Downside Scenario តម្រូវការកៅស៊ូធម្មជាតិលើពិភពលោក នឹងកើនឡើងប្រមាណ១,៦% ស្មើនឹង១៣,២៣លានតោននៅក្នុងឆ្នាំ២០១៨។

១០- យោងតាមការព្យាករណ៍របស់ IMF Scenario តម្រូវការកៅស៊ូសំយោគពិភពលោក ត្រូវបានគេរំពឹងថា នឹងកើនឡើងក្នុងអត្រាប្រមាណ២,៩% ស្មើនឹង១៥,៤លានតោន ក្នុងឆ្នាំ២០១៧ និងប្រមាណ៤,១% ស្មើនឹង១៦,០៤លានតោន ក្នុងឆ្នាំ២០១៨។ ដោយឡែក តាមការព្យាករណ៍របស់ Downside Scenario តម្រូវការកៅស៊ូសំយោគនឹងកើនឡើងប្រមាណ២,៧% ដែលមានបរិមាណដល់ទៅ១៥,៨២លានតោន ក្នុងឆ្នាំ២០១៨។

១១- តាមការព្យាករណ៍របស់ IMF Scenario កៅស៊ូធម្មជាតិត្រូវបានគេរំពឹងថា នឹងមានភាពប្រសើរឡើងវិញនៅឆ្នាំ២០១៨ ស្របតាមកំណើនសេដ្ឋកិច្ចពិភពលោក ក្នុងអត្រា៣,៧% ក្នុងឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៧ ដែលមានអត្រាត្រឹមតែ៣,៦% ប៉ុណ្ណោះ។ កំណើននេះ ដោយសារទីផ្សារដែលកំពុងរីកចម្រើន និងពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

១២- នៅក្នុងឆ្នាំ២០១៨ កំណើនសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក ត្រូវបានគេរំពឹងថា នឹងកើនឡើងក្នុងអត្រា២,៣% ធៀបនឹងឆ្នាំ២០១៧ មានអត្រា២,២% ដែលជាហេតុនាំឱ្យប្រទេសថៃ នាំចេញនូវផលិតផលទៅកាន់សហរដ្ឋ-អាមេរិក ជាពិសេសគ្រឿងបន្លាស់រថយន្ត។ ជាមួយគ្នានេះ ប្រទេសឥណ្ឌានឹងមានកំណើនសេដ្ឋកិច្ចលឿនជាងគេបំផុតនៅក្នុងតំបន់អាស៊ី ក្នុងអត្រា៧,៤% ក្នុងឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៧ ដែលមានអត្រាត្រឹម៦,៧%។ ប្រទេសប្រេស៊ីលដែលជាទីផ្សារកៅស៊ូដ៏សំខាន់មួយ ត្រូវបានគេរំពឹងថានឹងកើនឡើង១,៥% នៅក្នុងឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៧ មានអត្រាត្រឹម០,៧%។ រីឯកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិននឹងមាននិន្នាការធ្លាក់ចុះមកនៅត្រឹមអត្រា៦,៥% នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៧ ដែលមានអត្រាដល់ទៅ៦,៨% ដោយសារតែបំណុលបានបង្គរ (Accumulation of Debts) ហើយសេដ្ឋកិច្ចនៃប្រទេសជប៉ុននឹងមានកំណើនត្រឹម០,៧% នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៧ ដែលមានអត្រាដល់ទៅ១,៥%។

១៣- តាមទស្សនវិស័យកៅស៊ូធម្មជាតិ គេចាំបាច់ត្រូវផ្តោតលើកត្តាមួយចំនួនរួមមាន៖ ផលិតកម្ម តម្រូវការប្រើប្រាស់ និងអតិរេក។ អ្នកជំនាញសេដ្ឋកិច្ចផ្នែកកៅស៊ូ បានធ្វើការព្យាករថា ផលិតកម្មកៅស៊ូធម្មជាតិពិភពលោកក្នុងអំឡុងឆ្នាំ២០១៧-២០១៩ នឹងកើនឡើងក្នុងអត្រាប្រចាំឆ្នាំ៣,៧% ស្មើនឹង១៣,៩លានតោន នៅក្នុងឆ្នាំ២០១៩។ ការប្រើប្រាស់កៅស៊ូធម្មជាតិពិភពលោកសរុប នឹងមាននិន្នាការកើនឡើងក្នុងអត្រាទាបត្រឹម៣% ក្នុងឆ្នាំ២០១៧-២០១៩ ស្មើនឹង១៣,៧៥លានតោន នាចុងឆ្នាំ២០១៩។ ក្រុមសេដ្ឋបញ្ញាវ័ន្តបានព្យាករណ៍ថា ផលិតកម្មកៅស៊ូធម្មជាតិពិភពលោក នឹងមានកំណើនក្នុងអត្រាមធ្យមប្រចាំឆ្នាំ២% ក្នុងអំឡុងឆ្នាំ២០១៨-២០១៩ ទោះបីជាមានការព្យាកររបស់ក្រុមអ្នកសិក្សាស្រាវជ្រាវបាតុភូតធម្មជាតិ (la Nifia) ថានឹងមានកំណើន២,៣% ក្នុងអំឡុងឆ្នាំ២០១៨-២០១៩ ដោយសារកំណើននៃការលក់យានយន្តក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ចសកល។

១៤- សមាគមកៅស៊ូប្រទេសថៃ ប្រកាន់យកឥរិយាបថវិជ្ជមាន លើទស្សនវិស័យទីផ្សារកៅស៊ូធម្មជាតិ ដោយសារតែកៅស៊ូធម្មជាតិ បានជួយរួមចំណែកដល់កំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ក្រៅពីនេះក្រុមប្រឹក្សាកៅស៊ូត្រីភាគីអន្តរជាតិ (International Tripartite Rubber Council: ITRC) និងរដ្ឋាភិបាលថៃបានកំពុងដោះស្រាយតម្លៃកៅស៊ូដែលកំពុងធ្លាក់ចុះតាមគ្រោងការណ៍និងយន្តការជាច្រើន ដើម្បីរក្សាស្ថេរភាពតម្លៃកៅស៊ូធម្មជាតិ។ យន្តការទាំងនេះនឹងធានាបាននូវស្ថានភាពកៅស៊ូធម្មជាតិល្អប្រសើរ គួបផ្សំនឹងគ្រោងការណ៍ដែលបានសន្យារបស់ ITRC រួមមាន៖ (១)ផែនការគ្រប់គ្រងការផ្គត់ផ្គង់ (២)ផែនការកំណត់កូតានាំចេញដែលបានព្រមព្រៀង (៣)ផែនការជំរុញការប្រើប្រាស់ (៤)ការបង្កើតទីផ្សារក្នុងតំបន់ និង(៥)គម្រោងប្រកួតប្រជែងផ្តល់រង្វាន់ដល់អ្នកដែលមានគំនិតច្នៃប្រឌិតថ្មីនូវផលិតផលកៅស៊ូធម្មជាតិ។

១៥- លើសពីនេះទៅទៀត រដ្ឋាភិបាលថៃបានដាក់ចេញផែនការយុទ្ធសាស្ត្រកៅស៊ូធម្មជាតិរយៈពេល២០ឆ្នាំ(២០១៧-២០៣៦) ដើម្បីដោះស្រាយបញ្ហារចនាសម្ព័ន្ធ និងបង្កើតមូលដ្ឋានគ្រឹះនៃឧស្សាហកម្មកៅស៊ូធម្មជាតិសំដៅរក្សាកំណើនប្រកបដោយនិរន្តរភាពនាពេលអនាគត ក្រោមចក្ខុវិស័យ "ប្រទេសផលិតកៅស៊ូប្រកបដោយគុណភាព និងប្រាក់ចំណូលមានស្ថេរភាពសម្រាប់កសិករ"។

ចំណោមវិធានការរបស់រាជរដ្ឋាភិបាលថៃ ដើម្បីជួយដល់វិស័យកៅស៊ូធម្មជាតិ រួមមានដូចខាងក្រោម៖

១). ការគាំទ្រឥណទានសម្រាប់អ្នកផលិតកៅស៊ូ ក្នុងទឹកប្រាក់បន្ថែម១៥.០០០លានបាត
២). ការគាំទ្រឥណទានដល់ក្រុមកសិករ សម្រាប់កែច្នៃកៅស៊ូក្នុងទឹកប្រាក់៥.០០០លានបាត
៣).ការគាំទ្រឥណទានដល់កសិករសម្រាប់ការស្តុកទុកក្នុងទឹកប្រាក់១០.០០០លានបាត
៤).ការគាំទ្រឥណទានសម្រាប់អ្នកកែច្នៃកៅស៊ូក្នុងអត្រាការប្រាក់ទាបជាង៣%/ឆ្នាំ
៥).ការជំរុញបំរើបំរាស់កៅស៊ូនៅតាមទីភ្នាក់ងាររដ្ឋាភិបាល
៦).ការគ្រប់គ្រងផលិតកម្ម ក្នុងអំឡុងខែមករា-មីនា ឆ្នាំ២០១៨
៧).ការបង្កើតមូលនិធិស្ថេរភាពតម្លៃកៅស៊ូ។

១៦- សមាគមកៅស៊ូថៃមានជំនឿយ៉ាងមុតមាំថា ទំនាក់ទំនងយូរអង្វែងរវាងសាជីវកម្ម និងវិស័យដែលពាក់ព័ន្ធ ដូយ៉ាងដូចជា ទីភ្នាក់ងាររដ្ឋាភិបាល វិស័យឯកជន អ្នកដាំកៅស៊ូ ប្រតិបត្តិករកៅស៊ូនានា ព្រមទាំងប្រទេសផលិតកៅស៊ូធំទាំងបី ប្រទេសថៃ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងប្រទេសផលិតកៅស៊ូដទៃទៀត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាពិសេស ប្រទេសវៀតណាម ក្នុងការផ្តល់ទិសដៅ និងដំណោះស្រាយជាយុទ្ធសាស្ត្រចំពោះតម្លៃ ដែលកំពុងធ្លាក់ចុះសម្រាប់រយៈពេលខ្លីនិងវែង ដើម្បីរក្សាស្ថេរភាពតម្លៃកៅស៊ូធម្មជាតិ នៅលើទីផ្សារពិភពលោក។

## ២. លទ្ធផលការងារសំខាន់ៗ ក្នុងឆ្នាំ២០១៧

ក្នុងឆ្នាំ២០១៧កន្លងទៅ អគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់និងយ៉ាងសកម្ម ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

### ២.១ ការងាររដ្ឋបាលនិងនីតិកម្ម

### ២.១.១ ការងាររដ្ឋបាលនិងបុគ្គលិក

១៧- អនុក្រឹត្យលេខ១៨៨អនក្រ.បកចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូមានបេសកកម្មជានាការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យកៅស៊ូគ្រប់ផ្នែក ស្របតាមគោលនយោបាយ

របស់រាជរដ្ឋាភិបាល សំដៅរួមចំណែកជំរុញសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងសង្គម កាត់បន្ថយភាពក្រីក្រ លើកកម្ពស់គុណភាពផលិតផលកៅស៊ូ ដើម្បីធានាដល់ការប្រកួតប្រជែងនៅលើទីផ្សារ តាមរយៈការផ្តល់សេវាស្រាវជ្រាវ និងការផ្ទេរបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព ព្រមទាំងការអភិវឌ្ឍនិងការគ្រប់គ្រងខ្សែចង្វាក់ផលិតកម្ម អាជីវកម្មកែច្នៃសំដៅជំរុញពាណិជ្ជកម្មផលិតផលកៅស៊ូ។

១៨- អគ្គនាយកដ្ឋានកៅស៊ូ មានភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការងារជាអាទិ៍៖ រៀបចំ និងអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ ចក្ខុវិស័យ គោលដៅបេសកកម្ម និងកម្មវិធី អភិវឌ្ឍន៍វិស័យកៅស៊ូនៅកម្ពុជា សម្រាប់រយៈពេលមធ្យម និងវែង កសាងមូលដ្ឋានគតិយុត្ត លិខិតបទដ្ឋានច្បាប់ ស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍកៅស៊ូធានារាល់ដំណើរការផ្សេងៗទៀត ដែលមានការពាក់ពន្ធដល់វិស័យកៅស៊ូទូទាំងប្រទេស ព្រមទាំងភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ឱ្យ។

១៩- បានរៀបចំលិខិតចេញចំនួន១.១៣៨ច្បាប់ និងទទួលលិខិតចូលបានចំនួន១.១៨៩ច្បាប់។

២០- អគ្គនាយកដ្ឋានកៅស៊ូមាននាយកដ្ឋានជំនាញចំនួន០៥ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាចំនួន០១ជាសេនាធិការក្នុងការបំពេញភារកិច្ចទទួលខុសត្រូវតាមជំនាញសំដៅជំរុញ ពង្រឹង តាមដាន ស្រាវជ្រាវ និងអភិវឌ្ឍវិស័យកៅស៊ូនៅទូទាំងប្រទេស(ឧបសម្ព័ន្ធទី១)។

២១- អគ្គនាយកដ្ឋានមានមន្ត្រីរាជការសរុបចំនួន១៩២នាក់ ក្នុងនោះស្រីមានចំនួន៥៦នាក់ដែលកំពុងបម្រើការងារនៅតាមនាយកដ្ឋាន និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។ ការបែងចែកមន្ត្រីរាជការតាមកម្រិតជំនាញដូចមានខាងក្រោម៖

តារាងទី១ មន្ត្រីរាជការតាមកម្រិតជំនាញ

| ល.រ | បរិយាយ | កម្រិតសញ្ញាបត្រ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បណ្ឌិត | | អនុបណ្ឌិត | | បរិញ្ញាបត្រ | | មធ្យម | | គ្មាន | | សរុប | |
| | | ២០១៦ | ២០១៧ | ២០១៦ | ២០១៧ | ២០១៦ | ២០១៧ | ២០១៦ | ២០១៧ | ២០១៦ | ២០១៧ | ២០១៦ | ២០១៧ |
| ១ | ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ | ១ | ១ | ៣ | ៤ | | - | ១ | ១ | | - | **៥** | **៦** |
| ២ | នា.រដ្ឋបាល និងនីតិកម្ម | | - | ៤ | ៣ | ១៣ | ៨ | ៨ | ៤ | ១៧ | ១៧ | **៤២** | **៣២** |
| ៣ | នា.អភិវឌ្ឍន៍កៅស៊ូ | ១ | ១ | | ១ | ២៣ | ២២ | ១ | ២ | ៤ | ៤ | **២៩** | **៣០** |
| ៤ | នា.ផែនការ ហិរញ្ញវត្ថុ និងស្ថិតិ | | - | ៤ | ៤ | ១១ | ១៤ | ៣ | ៣ | ៦ | ៦ | **២៤** | **២៧** |
| ៥ | នា.កែច្នៃផលិតផលកៅស៊ូ | | - | ១ | ១ | ១១ | ១២ | ២ | ៤ | ៤ | ៤ | **១៨** | **២១** |
| ៦ | នា.ទីផ្សារ និងសហ.អន្តរជាតិ | | - | ២ | ២ | ១០ | ១៣ | ៤ | ៤ | ៧ | ៧ | **២៣** | **២៦** |
| ៧ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ១ | ១ | ១០ | ៨ | ២៩ | ២៨ | ៦ | ៦ | ៧ | ៧ | **៥៣** | **៥០** |
| | សរុប | **៣** | **៣** | **២៤** | **២៣** | **៩៧** | **៩៧** | **២៥** | **២៤** | **៤៥** | **៤៥** | **១៩៤** | **១៩២** |

២២- បានដំឡើងថ្នាក់ ឋានន្តរស័ក្តិមន្ត្រីរាជការចំនួន៣៦នាក់ និងផ្តល់គ្រឿងឥស្សរិយយសបានចំនួន២៣នាក់។

## ២.១.២ ការងារនីតិកម្ម

២៣- ក្នុងឆ្នាំ២០១៧ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ១៨០ប្រក.កសក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការគ្រប់គ្រងស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ដែលជាសមិទ្ធផលថ្មីមួយទៀតនៃការខិតខំប្រឹងប្រែង របស់អគ្គនាយកដ្ឋានកៅស៊ូក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងវិស័យកៅស៊ូឱ្យមានប្រសិទ្ធភាព។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានកៅស៊ូបានបន្តពិនិត្យ កែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ តាមស្មារតីអង្គប្រជុំអន្តរនាយកដ្ឋានក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បានចូលរួមដោះស្រាយទំនាស់ដីចម្ការកៅស៊ូដែលពាក់ព័ន្ធជាមួយបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ ក្នុងនោះបានចូលអនុវត្តសាលដីការក្សាការពាររបស់សាលាដំបូងខេត្តត្បូងឃ្មុំស្តីពី ទំនាស់ដីក្រុមហ៊ុនចម្ការកៅស៊ូសុភក្តិនីកា អ៊ីនវេសមេន គ្រុប ដែលត្រូវបានប្រជាពលរដ្ឋរំលោភចូលកាន់កាប់ និងបានចូលរួមដោះស្រាយទំនាស់ដីចម្ការកៅស៊ូឡាបានសៀក ខេត្តរតនគិរី។

## ២.១.៣ ការងារផ្សព្វផ្សាយ បណ្តុះបណ្តាល និងសិក្ខាសាលា

២៤- ការងារដែលបាននិងកំពុងអនុវត្តលើការបណ្តុះបណ្តាលជំនាញបច្ចេកទេសរួមមាន៖

១. បានចុះបើកវគ្គបណ្តុះបណ្តាលការបើកមុខចៀរដំបូង និងបច្ចេកទេសចៀរជ័រកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ បានចំនួន៦វគ្គ នៅខេត្តគោលដៅចំនួន០៦ខេត្តគឺ ខេត្តសៀមរាប ឧត្តរមានជ័យ ត្បូងឃ្មុំ ព្រៃវែង រតនគិរី និងមណ្ឌលគិរី ដោយមានកសិករចូលរួមសរុប៣០១នាក់។

២. បានចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ បានចំនួន០៨វគ្គ នៅខេត្តគោលដៅចំនួន៨ គឺខេត្តបាត់ដំបង ប៉ៃលិន រតនគិរី ស្ទឹងត្រែង សៀមរាប ឧត្តរមានជ័យ មណ្ឌលគិរី និងក្រចេះ ដោយមានកសិករចូលរួមសរុប៤១៣នាក់។

៣. បានចុះបើកវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយពីវិធានការបង្កើនថ្លៃកៅស៊ូធម្មជាតិក្នុងស្រុកដល់សហគមន៍កសិករកៅស៊ូគ្រួសារ បានចំនួន៦វគ្គ នៅខេត្តគោលដៅចំនួន៤ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តស្ទឹង-ត្រែង និងខេត្តក្រចេះ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៣០០នាក់ និងចុះស្រង់ទិន្នន័យថ្លៃដើមចំនួន៣លើក នៅខេត្តគោលដៅចំនួន៣ គឺខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។

៤. បានចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូចំនួន០២លើក នៅខេត្តគោលដៅចំនួន០២គឺត្បូងឃ្មុំ និងកំពង់ចាមដល់ម្ចាស់រោងចក្រ សិប្បកម្មកែច្នៃជ័រកៅស៊ូ មកពីខេត្តគោលដៅចំនួន០៩ គឺកំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងឧត្តរមានជ័យ ដោយមានម្ចាស់រោងចក្រ សិប្បកម្មចូលរួមសរុបចំនួន១២០នាក់។

៥. បានចុះបើកវគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់(Unsmoked sheet : USS) ដល់សហគមន៍កៅស៊ូគ្រួសារចំនួន៦លើក នៅខេត្តគោលដៅចំនួន៦ គឺបាត់ដំបង កំពង់ធំ ព្រះវិហារ ស្ទឹងត្រែង មណ្ឌលគិរី និងរតនគិរី។ ដោយមានម្ចាស់កៅស៊ូគ្រួសារចូលរួមសរុបចំនួន៣០១នាក់។

៦. បានចុះបើកវគ្គផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដល់ផ្នែកកៅស៊ូ នៅស្រុកគោលដៅចំនួន១០ក្នុង១០ខេត្តគឺ ខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ធំ រតនគិរី កោះកុង ព្រះវិហារ ស្ទឹងត្រែង ឧត្តរមានជ័យ បាត់ដំបង និងសៀមរាប ដោយមានប្រតិបត្តិករកៅស៊ូចូលរួមសរុប៤០០នាក់។

៧. បានបើកវគ្គបណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូចំនួន០១វគ្គ រយៈពេល០៣ថ្ងៃ ដោយមានប្រតិបត្តិករកៅស៊ូចូលរួមសរុប៣៥នាក់។

៨. បានបើកវគ្គបណ្តុះបណ្តាលបុគ្គលិកមន្ទីរពិសោធមូលដ្ឋាន និងបណ្តារោងចក្រក្រុមហ៊ុនចម្ការកៅស៊ូនានាក្នុងការកែច្នៃ និងការវិភាគគុណភាពជ័រសំដៅអភិវឌ្ឍផលិតកម្មដើម្បីឈានដល់ការសុំសិទ្ធិទទួលស្គាល់ពីមន្ទីរពិសោធជាតិយថាប្រភេទក្នុងការចេញវិញ្ញាបនបត្រ បញ្ជាក់គុណភាពកៅស៊ូ បានចំនួន៣ក្រុមហ៊ុនស្មើនឹង៣០នាក់។

៩. បានបណ្តុះបណ្តាលធនធានមនុស្ស និងផ្ទេរនូវបច្ចេកវិទ្យាតាមរយៈការសម្របសម្រួលទស្សនកិច្ចសិក្សាចំនួន២៥នាក់ (ខ្មែរចំនួន១៥នាក់ និងបរទេសចំនួន១០នាក់) និងបានដឹកនាំសរសេរសារណាបញ្ចប់ការសិក្សារបស់និស្សិតចំនួន០៨នាក់ និងបានបញ្ជូនមន្ត្រីចំនួន៦នាក់ ទៅបង្រៀននិស្សិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម។

១០.បានបើកវគ្គបណ្តុះបណ្តាលសមត្ថភាពជំនាញនិងចំណេះដឹងដល់គ្រូបង្គោលចំនួន២០នាក់ និងកសិករកៅស៊ូគ្រួសារចំនួន៣៤៥នាក់ លើមុខជំនាញផ្នែកផលិតកម្មកៅស៊ូបានចំនួន០៦វគ្គ សំដៅបង្កើនចំណេះដឹងលើវិជ្ជាជីវៈ ដើម្បីរក្សាបាននិរន្តរភាព ផលិតកម្មនិងស្ថិរភាពចំណូលរបស់កសិករ។

១១.បានចុះបើកវគ្គសិក្ខាសាលាស្តីពីការផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់មន្ត្រីបង្គោលចំនួន០១វគ្គ ដែលមានរយៈពេល០៣ថ្ងៃ នៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម ដែលមានមន្ត្រីមកពីការិយាល័យកៅស៊ូតាមបណ្តាខេត្តចំនួន២១ខេត្ត (ខេត្តរតនគិរី ត្បូងឃ្មុំ មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ ព្រៃវែង ស្វាយរៀង កំពង់ចាម កំពង់ធំ ព្រះវិហារ សៀមរាប ឧត្តរមានជ័យ ពោធិ៍សាត់ បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន កំពង់ស្ពឺ កំពត កោះកុង តាកែវ និងព្រះសីហនុ) សរុបចំនួន៣៥នាក់។

១២.បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីអគ្គនាយកដ្ឋានកៅស៊ូ និងមន្ត្រីការិយាល័យកៅស៊ូតាមខេត្ត ចំនួន៣វគ្គ ស្តីពី៖

- ស្ថានភាពឧស្សាហកម្មកៅស៊ូធម្មជាតិពិភពលោក ដោយមានអ្នកចូលរួមសរុបចំនួន៤០នាក់
- នីតិវិធីប្រមូលទិន្នន័យស្ថិតិ និងព័ត៌មានកៅស៊ូ ដោយមានអ្នកចូលរួមសរុបចំនួន៤០នាក់
- ការរៀបចំថវិកាកម្មវិធីដល់មន្ត្រីរាជការ ដោយមានអ្នកចូលរួមសរុប៣០នាក់។

១៣.បានរៀបចំវគ្គសិក្ខាសាលាផ្សព្វផ្សាយស្តីពីវិធានការពង្រឹងការគ្រប់គ្រងវិស័យកៅស៊ូធម្មជាតិ នៅសាលាខេត្តត្បូងឃ្មុំ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធសរុបចំនួន១៧០នាក់។

១៤.បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីអំពី " អនុសាស្ត្រក្លូនកៅស៊ូនៅកម្ពុជា សម្រាប់ឆ្នាំ២០១៨-២០២០ " ដោយមានអ្នកចូលរួមសរុបចំនួន៥៨នាក់។

១៥.បានរៀបចំសិក្ខាសាលាអន្តរជាតិចំនួន០១លើក ក្រោមប្រធានបទ "ការផ្ទេរបច្ចេកវិទ្យាដល់ផលិតករកៅស៊ូ និងកសិករកៅស៊ូគ្រួសារ" ដោយមានអ្នកចូលរួមចំនួន១៦៩នាក់។

១៦.- បានចុះពង្រឹងសហគមន៍កៅស៊ូគ្រួសារបានចំនួន៤សហគមន៍ នៅខេត្តគោលដៅចំនួន០៤គឺ ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង

- បានចងក្រងសហគមន៍កៅស៊ូគ្រួសារចំនួន២ ថ្មីបន្ថែមទៀត នៅក្នុងខេត្តគោលដៅចំនួន០២គឺ ខេត្តបាត់ដំបង និងខេត្តប៉ៃលិន។

១៧.- ផ្សាយតម្លៃកៅស៊ូតាមវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (FM102) ៤៨ដង/ឆ្នាំ (១ដង/សប្តាហ៍) ដើម្បីឱ្យកសិករកៅស៊ូគ្រួសារ និងប្រតិបត្តិករកៅស៊ូក្តាប់បានតម្លៃជ័រកៅស៊ូក្នុងស្រុក និងក្រៅស្រុក

- បានបោះពុម្ពព្រឹត្តិបត្រកៅស៊ូធម្មជាតិចំនួន២.១៥៩ច្បាប់ សម្រាប់ចែកជូនកសិករកៅស៊ូគ្រួសារ និងអ្នកពាក់ព័ន្ធដែលជាចំណេះដឹងបន្ថែមអំពីវិស័យកៅស៊ូ។

២៥- ការចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ៖

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "កិច្ចបញ្ជីការជូនទេយ្យចំណូល-ចំណាយ សម្រាប់ថវិកាកម្មវិធីរដ្ឋបាលថ្នាក់ជាតិ និងរបាយការណ៍អនុវត្តចំណូល-ចំណាយឆ្នាំ២០១៦" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៣-២៤ ខែមីនា ឆ្នាំ២០១៧ នៅខេត្តសៀមរាប
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ពង្រឹងសមត្ថភាពមន្ត្រីរាជការលើការងាររដ្ឋបាល និងបុគ្គលិក" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី០៤ ដល់០៦ ខែតុលា ឆ្នាំ២០១៧នៅខេត្តកំពត
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ប្រព័ន្ធតាមដាន និងវាយតម្លៃថវិកាកម្មវិធី" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៦ ដល់២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅខេត្តបាត់ដំបង
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ប្រព័ន្ធគ្រប់គ្រងគុណផល" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៦ ដល់២៧ ខែធ្នូ ឆ្នាំ២០១៧ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២៦- ការចូលរួមវគ្គសិក្ខាសាលាផ្សេងៗ៖

- បានចូលរួមវគ្គសិក្ខាសាលាស្តីពី "យន្តការ នីតិវិធី និងរបៀបប្រើប្រាស់ការបញ្ចូលព័ត៌មានទិន្នន័យ កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលតាមប្រព័ន្ធគ្រប់គ្រងអ៊ីនឡាញ" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី០១-០៣ ខែមីនា ឆ្នាំ២០១៧ នៅខេត្តព្រះសីហនុ
- បានចូលរួមវគ្គសិក្ខាសាលាស្តីពី "ការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៨" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី៣០-៣១ ខែមីនា ឆ្នាំ២០១៧ នៅខេត្តកំពង់ចាម
- បានចូលរួមវគ្គសិក្ខាសាលាស្តីពី "ពិគ្រោះយោបល់លើកចុងក្រោយទៅលើគោលការណ៍ណែនាំស្តីពីការរៀបចំផែនការ និងប្រព័ន្ធតាមដាននិងវាយតម្លៃ" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៣-២៥ ខែសីហា ឆ្នាំ២០១៧ នៅខេត្តកំពង់ធំ
- បានចូលរួមវគ្គសិក្ខាសាលាស្តីពី "លទ្ធផលនៃការអនុវត្តថវិកាកម្មវិធីដោយផ្អែកលើប្រព័ន្ធតាមដាន និងវាយតម្លៃ" ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១៣ ដល់១៥ ខែធ្នូ ឆ្នាំ២០១៧ នៅខេត្តសៀមរាប។

## ២.២ ការងារផែនការនិងហិរញ្ញវត្ថុ

### ២.២.១ ការងារផែនការ

២៧- ដើម្បីសម្រេចគោលបំណង និងគោលដៅវិស័យកសិកម្មដែលបានកំណត់ក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ពិសេសផ្នែកកៅស៊ូ អគ្គនាយកដ្ឋានកៅស៊ូដែលជាសេនាធិការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តអនុកម្មវិធីចំនួន៦ ដែលក្នុងនោះមានចង្កោមសកម្មភាពចំនួន១៩សម្រាប់ទ្រទ្រង់និងអនុវត្ត៖

១. អនុកម្មវិធីទី១.១១៖ ជំរុញការវិនិយោគនិងអភិវឌ្ឍន៍ដំណាំកៅស៊ូ ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់និងចីរភាព

- ១.១១.១ ផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារនិងមន្ត្រីបង្គោល
- ១.១១.២ ចងក្រង និងពង្រឹងសហគមន៍កសិករកៅស៊ូគ្រួសារ
- ១.១១.៣ សិក្សាលក្ខណៈសម្បត្តិ ( Profile) ចម្ការកៅស៊ូគ្រួសារ
- ១.១១.៤ ចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។

២. អនុកម្មវិធីទី១.១២៖ ជំរុញខ្សែចង្វាក់តម្លៃកៅស៊ូឱ្យបានល្អ

- ១.១២.១ បណ្តុះបណ្តាល និងផ្សព្វផ្សាយពីទីផ្សារកៅស៊ូដល់សហគមន៍កៅស៊ូគ្រួសារឲ្យបង្កើតមជ្ឈមណ្ឌលលក់ដូរកៅស៊ូរួម
- ១.១២.២ ផ្តល់ព័ត៌មានពីការផ្គត់ផ្គង់តម្រូវការ និងតម្លៃកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ។

៣.អនុកម្មវិធីទី១.១៣៖ លើកកម្ពស់គុណភាពផលិតផលកៅស៊ូ

- ១.១៣.១ ផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ
- ១.១៣.២ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក(USS)ដល់សហគមន៍កៅស៊ូគ្រួសារ

៤. អនុកម្មវិធីទី១.១៤៖ លើកកម្ពស់ការគ្រប់គ្រងនិងបណ្តុះបណ្តាលធនធានមនុស្សក្នុងផ្នែកកៅស៊ូ។

- ១.១៤.១ រៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូនិងលិខិតបទដ្ឋានក្រោមច្បាប់
- ១.១៤.២ ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធវិស័យកៅស៊ូ
- ១.១៤.៣ បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ។

៥. អនុកម្មវិធីទី១.១៥៖ ពង្រឹងការកសាង ការអនុវត្តផែនការនិងអភិបាលកិច្ចក្នុងអនុវិស័យកៅស៊ូ

- ១.១៥.១ តាមដានវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព
- ១.១៥.២ តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធី វិនិយោគដីសម្បទានសេដ្ឋកិច្ចលើវិស័យកៅស៊ូ
- ១.១៥.៣ គាំទ្រការសម្របសម្រួលការងារនិងរៀបចំប្រជុំបូកសរុបការងារ។

៦. អនុកម្មវិធីទី១.១៦៖ លើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ

- ១.១៦.១ សិក្សាស្រាវជ្រាវក្នុងការបង្កាត់និងជម្រើសពូជ គ្រប់គ្រងច្បារពូជ និងអភិវឌ្ឍក្លូនកៅស៊ូប្រកបដោយប្រសិទ្ធភាពនិងបន្សាំបម្រែបម្រួលអាកាសធាតុក្នុងលក្ខខណ្ឌប្រទេសកម្ពុជា
- ១.១៦.២ សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកទេសកសិកម្មល្អ ក្នុងការដាំដុះនិងថែទាំដំណាំកៅស៊ូទាំងមុននិងក្រោយការប្រមូលផល
- ១.១៦.៣ សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកទេសប្រមូលផលជ័រកៅស៊ូ ប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាពនៃការលូតលាស់ក្នុងវដ្តសេដ្ឋកិច្ចដំណាំកៅស៊ូ
- ១.១៦.៤ ធ្វើតេស្តបញ្ជាក់គុណភាពកៅស៊ូអន្តរមន្ទីរពិសោធន៍ជាមួយ IRA បណ្តាមន្ទីរពិសោធន៍ក្នុងស្រុក និងចុះត្រួតពិនិត្យរោងចក្រ CSR និង Lab CSR
- ១.១៦.៥ ទទួលធ្វើសាវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យទទួលស្គាល់ជាផ្លូវការអន្តរជាតិវិភាគទាន IRRDB និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។

២៨- ឆ្នាំ២០១៧ ជាឆ្នាំមួយដែលអនុវត្តប្រព័ន្ធថវិកាថ្មី គឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ជាពិសេសលទ្ធផលដែលអនុវត្តបាន ត្រូវវាស់វែងផ្អែកលើគោលដៅសូចនាករ។ សមិទ្ធផលផ្នែកកៅស៊ូដែលសម្រេចបានតាមបណ្តាចង្កោមសកម្មភាពនៃអនុកម្មវិធីនីមួយៗរបស់ថវិកាកម្មវិធីក្នុងឆ្នាំនេះ អាចវាយតម្លៃបានថា មានការរីកចម្រើនគួរជាទីមោទកភាព (ឧបសម្ព័ន្ធទី២)។

២៩- បានរៀបចំកសាងគម្រោងផែនការថវិកាកម្មវិធីឆ្នាំ២០១៨ សម្រាប់អគ្គនាយកដ្ឋានកៅស៊ូទាន់ពេលវេលា និងទទួលបានការអនុម័តយល់ព្រមផ្តល់ថវិកាសម្រាប់គម្រោងថវិកាកម្មវិធី ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានអនុកម្មវិធីចំនួន៣ និងចង្កោមសកម្មភាពចំនួន១២ ក្នុងនោះវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាមាន១អនុកម្មវិធី ដែលមានចង្កោមសកម្មភាពចំនួន០៣ (ឧបសម្ព័ន្ធទី៣)។

៣០- បានបញ្ចប់កិច្ចប្រជុំពិភាក្សាក្រុមការងារស្តីពីការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា និងត្រៀមដាក់ឆ្លងថ្នាក់ដឹកនាំដើម្បីពិនិត្យ កែសម្រួល។

៣១- បានចេញលិខិតអនុញ្ញាតសុំបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ និងបានចុះពិនិត្យទីតាំងស្នើសុំបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូថ្មីបន្ថែមទៀត។

## ២.២.២ ការងារហិរញ្ញវត្ថុ

៣២- រៀបចំគម្រោងចំណាយថវិកាកម្មវិធី និងស្នើសុំគោលការណ៍ចំណាយថវិការជូនទេយ្យបុរេប្រទានសម្រាប់អនុវត្តក្នុងឆ្នាំ។ រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និងស្នើសុំគោលការណ៍ធានាចំណាយថវិកាលើការងារលទ្ធកម្មទូទៅ ប្រេងឥន្ធនៈ សម្ភារការិយាល័យ សង្ហារឹម ឧបករណ៍បច្ចេកទេស សំលៀកបំពាក់ស្វ័យការពារ ជួសជុលរថយន្ត និងជួសជុលអាគារ ធ្វើការដេញថ្លៃ និងធ្វើការប្រគល់ ទទួលបានរួចក្នុងឆ្នាំ។ រៀបចំសក្ខីប័ត្របញ្ចប់លើការងារទូទាត់ថវិកាកម្មវិធីទាំង៤ជំហ៊ាន។ រៀបចំការចុះបញ្ជីសារពើភ័ណ្ឌកើន ថយ ទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋានកៅស៊ូ។

៣៣- ធ្វើការជាប្រចាំជាមួយនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ ស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការរៀបចំឯកសារនានាពាក់ព័ន្ធ ចំណាយថវិកានិងអនុវត្តគម្រោងផែនការ និងការចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋានកៅស៊ូ។

៣៤- ថវិកាអនុម័តឆ្នាំ២០១៧ មានចំនួន២.៨៩៧,៧លានរៀល ធៀបនឹង២០១៦ មានចំនួន២.៨៦៨លានរៀល គឺមានការកើនឡើង២៩,៧លានរៀល ស្មើនឹង១,០៤%។ ក្នុងនោះជំពូក៦៤ ជាការចំណាយទៅលើបន្ទុកបុគ្គលិកមានការកើនឡើងចំនួន២១,៧លានរៀល ជំពូក៦៥ ការឧបត្ថម្ភធន និងជំនួយសង្គមកើនឡើងចំនួន ១០លាន ជំពូក៦៣ ពន្ធនិងអាករ មានការថយចុះចំនួន២លានរៀល ដោយឡែកជំពូក៦០ ការទិញ និងជំពូក៦១ សេវាខាងក្រៅគឺមិនមានការប្រែប្រួលទេ។




ដ្យាក្រាមទី១ ការប្រៀបធៀបថវិកាអនុម័តឆ្នាំ២០១៦ និង២០១៧

៣៥- ការអនុវត្តថវិកាប្រចាំឆ្នាំសម្រាប់ការអភិវឌ្ឍដំណាំកៅស៊ូ (លើកលែងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា) ក្នុងរយៈពេល៨ឆ្នាំនេះ គិតពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៧ មានការកើនឡើងជាលំដាប់ក្នុងកម្រិតប្រមាណ១២,៣% ក្នុង

១ឆ្នាំ។ បើធៀបនឹងថវិកាអនុម័ត ការអនុវត្តថវិកាក្នុងរយៈពេល៨ឆ្នាំសម្រេចបានពី៩៦,៩៣% ទៅ១២៤,៩៥%។ ការចំណាយខ្ពស់ដល់ទៅ១២៤,៩៥%នេះ បណ្តាលមកពីមានការចំណាយលើសនៃបន្ទុកបុគ្គលិក ប៉ុន្តែជារួម កម្រិតអនុវត្តផែនការថវិកាទាំងនេះ អាចចាត់ទុកថាបានអនុវត្តក្នុងកម្រិតល្អ។




ដ្យាក្រាមទី២ ការប្រៀបធៀបថវិកាអនុវត្តនិងថវិកាអនុម័តឆ្នាំពី២០១០-២០១៧

៣៦- ការប្រមូលចំណូលរបស់អគ្គនាយកដ្ឋានកៅស៊ូ បានមកពីការជួលដីរបស់ក្រុមហ៊ុនអភិនិយោគទាំង០៧ ការជួលដីសហគ្រាសសាធារណៈថ្នាក់រដ្ឋបាលកណ្តាល (ចម្ការកៅស៊ូឡាបានសៀក) និងការជួលអចលនវត្ថុ (អសង្ហារឹម) ក្រុមហ៊ុននីហាវ័ណ អាហាវ័ណកៅស៊ូ។ ក្នុងឆ្នាំ២០១៧ អនុវត្តបានចំនួន១.៤៦៦.០៤២.០១០រៀល (៣៦៣.៣៩២,៣៤ដុល្លារអាម៉េរិក) បើធៀបនឹងគោលដៅចំនួន១.៤០៣.០០០.០០០រៀល (៣៤៦.៤១៩,៧៥ ដុល្លារអាម៉េរិក) មានកើនឡើងចំនួន៦៣.០៤២.០១០រៀល (១៥.៥៦៥,៩៣ដុល្លារអាម៉េរិក) ស្មើនឹង៤,៤៩% (ឧបសម្ព័ន្ធទី១៥)។

៣៧- រៀបចំឯកសារនានាពាក់ព័ន្ធនឹងការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋក្នុងការិយបរិច្ឆេទឆ្នាំ២០១៦។

៣៨- សហការជាមួយគណៈប្រតិភូអធិការកិច្ចសវនកម្មផ្ទៃក្នុងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈប្រតិភូអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច គណៈប្រតិភូអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ (ការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ) ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋក្នុងការិយបរិច្ឆេទឆ្នាំ២០១៦ និងបណ្តាឆ្នាំពាក់ព័ន្ធ។

## ២.៣ ការងារអភិវឌ្ឍន៍

### ២.៣.១ ស្ថិតិផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ

៣៩- នៅឆ្នាំ២០១៧នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបចំនួន៤៣៦.៣៤០ហិកតា បើធៀបទៅនឹងឆ្នាំ២០១៦ មានចំនួន៤៣២.៧៣៥ហិកតា កើនឡើងចំនួន៣.៦០៥ហិកតា ស្មើនឹង០,៨៣%។ ផ្ទៃដីកៅស៊ូទាំងនេះត្រូវបានបែងចែក

ជា០២ផ្នែកគឺៈ ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម(អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន២៨០.២២៨ហិកតា ស្មើនឹង៦៤,២២% និងកៅស៊ូគ្រួសារមានចំនួន១៥៦.១១២ហិកតា ស្មើនឹង៣៥,៧៨% នៃផ្ទៃដីកៅស៊ូសរុប(តារាងទី២ ដ្យាក្រាមទី៣ និងដ្យាក្រាមទី៤)។

តារាងទី២ ស្ថិតិផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៧ (ហិកតា)

| ប្រភេទចម្ការកៅស៊ូ | ចៀរជ័រ | ថែទាំ | សរុប | ភាគរយ |
|---|---|---|---|---|
| **១.ចម្ការកៅស៊ូកសិឧស្សាហកម្ម** | ៦៩.៧២៦ | ២១០.៥០២ | ២៨០.២២៨ | ៦៤,២២ |
| -អតីតចម្ការកៅស៊ូរដ្ឋនិងវ.ស.ក.ក. | ៣៤.៤៩៧ | ១៨.១៩៩ | ៥២.៦៩៦ | ១២,០៧ |
| -ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | ៣៥.២២៩ | ១៩២.៣០៣ | ២២៧.៥៣២ | ៥២,១៥ |
| **២. ចម្ការកៅស៊ូគ្រួសារ** | ១០០.៥០៤ | ៥៥.៦០៨ | ១៥៦.១១២ | ៣៥,៧៨ |
| សរុប | **១៧០.២៣០** | **២៦៦.១១០** | **៤៣៦.៣៤០** | **១០០** |

សម្គាល់ៈ វ.ស.ក.ក.ៈ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា




ដ្យាក្រាមទី៣ អត្រាភាគរយនៃប្រភេទផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០១៧(ហិកតា)




ដ្យាក្រាមទី៤ ទំហំប្រភេទផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៣-២០១៧ (ហិកតា)

៤០- ឆ្នាំ២០១៧នេះ ផ្ទៃដីកៅស៊ូចៀរអនុវត្តបានចំនួន១៧០.២៣០ហិកតា ធៀបនឹងផ្ទៃដីកៅស៊ូចៀរឆ្នាំ២០១៦ មាន ១២៦.៩៩៦ហិកតា កើនឡើងចំនួន៤៣.២៣៤ហិកតា ស្មើនឹង៣៤,០៤% (ដ្យាក្រាមទី៥)។ ផលិតផលកៅស៊ូ សម្រេចបានចំនួន១៩៣.២៨៦តោន ធៀបនឹងឆ្នាំ២០១៦ ចំនួន១៤៥.២០០តោន កើនឡើងចំនួន៤៨.០៨៦ តោន ស្មើនឹង៣៣,១១%។ ទិន្នផលមធ្យមចំនួន ១.១៣៥គ.ក្រ./ហ.ត. ធៀបនឹងឆ្នាំ២០១៦ មានចំនួន ១.១៤៣គ.ក្រ./ហ.ត. គឺថយចុះ០,៧% (ឧបសម្ព័ន្ធទី៤)។ ចំណែកស្ថិតិផ្ទៃដីកៅស៊ូលម្អិតមានបង្ហាញជូនក្នុង ឧបសម្ព័ន្ធទី៥ ទី៦ ទី៧ ទី៨ ទី៩ ទី១០ ទី១១ ទី១៣និងទី១៤។




ដ្យាក្រាមទី៥ ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុប ឆ្នាំ២០១៣-២០១៧(ហិកតា)

៤១- ការនាំចេញកៅស៊ូធម្មជាតិឆ្នាំ២០១៧ សម្រេចបានចំនួន១៨៨.៨៣២តោន ស្មើនឹងទឹកប្រាក់ចំនួន ២៩៩.៣៩៤.៨៤១ដុល្លារអាម៉េរិក បើធៀបនឹងឆ្នាំ២០១៦ ដែលការនាំចេញមានចំនួន១៤៥.១០០តោន ស្មើនឹងទឹកប្រាក់ចំនួន១៨៧.១៦៤.៥៥១ដុល្លារអាម៉េរិច គឺផលិតផលកៅស៊ូធម្មជាតិនាំចេញកើនឡើងចំនួន ៤៣.៧៣២តោន ស្មើនឹង៣០,១៤%។ ទឹកប្រាក់ចំណូលកើនប្រមាណ១១២.២៣០.២៨៩ដុល្លារអាម៉េរិក ស្មើនឹង៥៩,៩៦% ដោយសារ (១)អង្គការ OPEC បានសម្រេចកាត់បន្ថយបរិមាណផលិតប្រេងនៅរយៈពេល៦ ខែនិងគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅភាគខាងត្បូងនៃប្រទេសថៃ (២)អត្រាកំណើននៃសេដ្ឋកិច្ចពិភពលោកក្នុង ឆ្នាំ២០១៧ (៣)ប្រទេសជាសមាជិកសមាគម ANRPC បានឯកភាពគ្នាលើការកាត់បន្ថយបរិមាណផលិត ដើម្បីរក្សាស្ថេរភាពតម្លៃជ័រកៅស៊ូធម្មជាតិ។




ដ្យាក្រាមទី៦ ផលិតកម្មនិងការនាំចេញកៅស៊ូធម្មជាតិឆ្នាំ២០១៣-២០១៧

## ២.៣.២ ស្ថិតិរោងចក្រ និងសិប្បកម្មកែច្នៃផលិតផលកៅស៊ូធម្មជាតិ

៤២- នៅក្នុងឆ្នាំ២០១៣មានរោងចក្រ សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូចំនួន៧០កន្លែង ក្នុងនោះរោងចក្រកែច្នៃកៅស៊ូដុំ (TSR: Technically Specified Rubber) ចំនួន៣០កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកក្រឡាសម្ងួតដោយផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅគ្មានផ្សែង (ADS: Air-Dried Sheet) មានចំនួន៣៦កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន០៤កន្លែង។ នៅក្នុងឆ្នាំ២០១៤មានរោងចក្រ សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូចំនួន៩៨ កន្លែង ក្នុងនោះរោងចក្រកែច្នៃកៅស៊ូដុំ (TSR: Technically Specified Rubber) ចំនួន៣៤កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកក្រឡាសម្ងួតដោយផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅគ្មានផ្សែង (ADS: Air-Dried Sheet) មានចំនួន៦០កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន០៤កន្លែង។ នៅក្នុងឆ្នាំ២០១៥មានរោងចក្រ សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូចំនួន១២០កន្លែង ក្នុងនោះរោងចក្រកែច្នៃកៅស៊ូដុំ (TSR: Technically Specified Rubber) ចំនួន៣៦កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកក្រឡាសម្ងួតដោយផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅគ្មានផ្សែង (ADS: Air-Dried Sheet) មានចំនួន៨០កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន០៤កន្លែង។ នៅក្នុងឆ្នាំ២០១៦ មានរោងចក្រ សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូចំនួន១២៦កន្លែង ក្នុងនោះរោងចក្រកែច្នៃកៅស៊ូដុំ (TSR: Technically Specified Rubber) ចំនួន៣៧កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកក្រឡាសម្ងួតដោយផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅគ្មានផ្សែង (ADS: Air-Dried Sheet) មានចំនួន៨៥កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន០៤កន្លែង។ នៅក្នុងឆ្នាំ២០១៧ មានរោងចក្រ សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូចំនួន១៣៩កន្លែង ក្នុងនោះរោងចក្រកែច្នៃកៅស៊ូដុំ (TSR: Technically Specified Rubber) ចំនួន៣៧កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ចំនួន០១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកក្រឡាសម្ងួតដោយផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹក

សម្ងួតដោយខ្យល់ក្ដៅគ្មានផ្សែង (ADS: Air-Dried Sheet) មានចំនួន៩២កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន០៩កន្លែង ។




ដ្យាក្រាមទី៧ ចំនួនរោងចក្រ សិប្បកម្មកែច្នៃជ័រ និងឈើកៅស៊ូ២០១៣-២០១៧

៤៣- អត្រាគុណភាពផលិតផលកៅស៊ូក្នុងឆ្នាំ២០១៣ មានចំនួន៧១ភាគរយ ក្នុងឆ្នាំ២០១៤ មានចំនួន៧៣ភាគរយ ឆ្នាំ២០១៥ មានចំនួន៧៥ភាគរយ ឆ្នាំ២០១៦ មានចំនួន៧៦,៦៣ភាគរយ និងក្នុងឆ្នាំ២០១៧ មានចំនួន៧៧ភាគរយ(ឧបសម្ព័ន្ធទី១២)។




ដ្យាក្រាមទី៨ អត្រាគុណភាពផលិតផលកៅស៊ូ២០១៣-២០១៧

## ២.៤ ការងារពិសោធន៍និងស្រាវជ្រាវ

៤៤- ការងារស្រាវជ្រាវនិងពិសោធន៍ បានចូលរួមជំរុញការអភិវឌ្ឍលើគ្រប់ផ្នែកដំណាំកៅស៊ូទាំងផ្នែកបច្ចេកទេសសុវុឌ្ឍិកម្មក្លូនកៅស៊ូ គុណភាពជ័រកៅស៊ូ និងតម្លៃផលិតកម្ម។ ការអនុវត្ត និងបន្តការងារស្រាវជ្រាវតាមដានទិន្នន័យចម្ការពិសោធន៍នៅក្នុងស្ថានីយ៍ និងនៅតាមបណ្ដាក្រុមហ៊ុនចម្ការកៅស៊ូ សរុបមានចំនួន៦០ពិសោធន៍។ ក្នុងការបង្កើនផលិតភាពកៅស៊ូ ដល់ការអភិវឌ្ឍក្លូនកៅស៊ូ ដោយបានចូលរួមក្នុងកម្មវិធីប្ដូរក្លូនពហុភាគីរវាងប្រទេសជាសមាជិក IRRDB ក្នុងនោះកម្ពុជាបានផ្ញើក្លូន CMS ចំនួន០៥ទៅឱ្យប្រទេសឥណ្ឌានិងប្រទេសថៃ

និងទទួលបានមកវិញនូវក្លូនកៅស៊ូចំនួន០៥ ពីប្រទេសឥណ្ឌា និង០៥ពីប្រទេសថៃ ហើយនិងក្លូនCMS ចំនួន ០៣ បន្ថែមទៀតពី CIRAD តាមរយៈប្រទេសហ្គាណា។ ទន្ទឹមគ្នានឹងការស្រាវជ្រាវបានរួមចំណែកយ៉ាងធំធេង នៅក្នុងការបណ្តុះបណ្តាលនិងផ្ទេរបច្ចេកវិទ្យាដល់កសិករកៅស៊ូគ្រួសារ ប្រតិបត្តិករកៅស៊ូ សំដៅបង្កើនផលិតភាព កៅស៊ូ និងការប្រមូលផល ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីកំណើនសេដ្ឋកិច្ចជាតិ សង្គម ព្រម ជាមួយគ្នានោះដែរក៏មានការបណ្តុះបណ្តាលធនធានមនុស្សនៅតាមគ្រឹះស្ថានសិក្សា សម្រាប់បន្តវេនក្នុងការ អភិវឌ្ឍដំណាំកៅស៊ូ។

៤៥ ការងារដែលបាននិងកំពុងអនុវត្តលើការស្រាវជ្រាវផ្នែកក្សេត្រសាស្ត្រ៖

- ការស្រង់ទិន្នន័យបញ្ចូល និងវិភាគទិន្នន័យគ្រប់ចម្ការពិសោធចំនួន៥៩ ក្នុងបរិវេណស្ថានីយ៍អនុវត្ត និងនៅតាម បណ្តាក្រុមហ៊ុនចម្ការកៅស៊ូ
- ការរៀបចំរបាយការណ៍បច្ចេកទេសប្រចាំឆ្នាំ២០១៦-២០១៧
- ការរៀបចំកូនកៅស៊ូទម្រង់០១ឆ័ត្រស្លឹក ចំនួន១៤.០០០ដើម ដោយក្លូន FDR 5788 និង MDX 624 សម្រាប់ ការដាំដុះចម្ការពិសោធ
- ការបំប៉ោកូនកៅស៊ូចំនួន១.០១៧ ដើម ដែលទទួលបានពីការផ្លាស់ប្តូរក្លូនកៅស៊ូ IRRDB
- ការដាំជួសកូនកៅស៊ូនៅចម្ការពិសោធក្នុងស្ថានីយ៍ចំនួន១៩ហិកតា
- ការថែទាំកូនកៅស៊ូចម្ការពិសោធចំនួន៥៥,៧៦ហិកតា
- ការរៀបចំដី និងដាំដុះចម្ការពិសោធថ្មីក្លូន CMS ចំនួន១២,៥ហិកតា
- ការរៀបចំដី និងដាំដុះចម្ការពិសោធក្លូនទ្រង់ទ្រាយតូច SSCT 02 (20 genotypes) ចំនួន១,៤ហិកតា
- ការរៀបចំដី និងដាំដុះចម្ការពិសោធវាយតម្លៃស៊ីដលីង SET 02 (20 genotypes) ចំនួន 0,៣ហិកតា
- ការរៀបចំថ្នាលបណ្តុះកូនកៅស៊ូថ្មីសម្រាប់ឆ្នាំ២០១៧-២០១៨ ចំនួន0,៣៥ហិកតា
- ការថែទាំចម្ការសមុច្ច័យដំណាំគ្របដីចំនួន១៧ ប្រភេទ
- ការដាក់ជីបំប៉នកូនកៅស៊ូចំនួនពីរលើកលើផ្ទៃដី៦៨ហិកតា
- ការស្រង់ទិន្នន័យជំងឺ Oidium នៅតាមបណ្តាចម្ការពិសោធក្លូនចំនួន២៦ពិសោធន៍
- ការស្រង់ទិន្នន័យដើមកៅស៊ូកើតជំងឺស្ងួតផ្ទាំងចៀរ(TPD)នៅតាមបណ្តាចម្ការពិសោធសរីរសាស្ត្រ និងអាជីវកម្ម ចំនួន១៤ពិសោធន៍
- ការបាញ់ថ្នាំព្យាបាលជំងឺ Pink Disease នៅតាមប្រគៀបមែកកៅស៊ូចាប់ពីកៅស៊ូអាយុ០៣-១០ឆ្នាំ ចំនួន០៣ជុំ លើផ្ទៃដីចំនួន១៦២ហិកតា
- ការបង្កើតច្បារពូជថ្មីក្រោមគម្រោងធម្មនិយាមកម្មចំនួន0,៤៨ហិកតា
- ការលាបថ្នាំពណ៌ឡើងវិញ ដើម្បីសម្គាល់គល់ពូជដែលបានបញ្ជាក់ភាពត្រឹមត្រូវដោយការវិភាគ DNA
- ក្រុមប្រតិបត្តិគម្រោងធម្មនិយាមកម្មចុះត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃច្បារពូជកៅស៊ូ ក្រោយពីការវិភាគ DNA និងការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជឯកជន បានចំនួន១០ច្បារពូជ
- ការចុះយកសំណាកស្លឹកកៅស៊ូដោយក្រុមអនុវត្តគម្រោងធម្មនិយាមកម្មច្បារពូជនៅកម្ពុជា ដើម្បីវិភាគDNA បានចំនួន១.០៣០សំណាក
- ការវិភាគ DRC និង TSC ចំនួន០៣ដង គ្រប់ចម្ការពិសោធក្នុងស្ថានីយ៍ ដោយមេត្រូឡាក់និងការដុតក្នុងបន្ទប់ ពិសោធ
- ការវិភាគ LD គ្រប់ចម្ការពិសោធក្នុងស្ថានីយ៍បានចំនួន៤៦៤សំណាក

- ផ្ទៀងផ្ទាត់គុណភាពវត្ថុធាតុគីមី សម្រាប់វិភាគសរីរសាស្ត្រទឹកជ័រចំនួន១៧លើក
- បានចេញវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជឯកជនសរុប១៩ ក្នុងនោះឆ្នាំ២០១៧ មានចំនួន១០ច្បារពូជ។

៤៦- ការងារក្នុងផ្នែកមន្ទីរពិសោធយថាប្រភេទ៖

- ការប្រមូលជ័រគម្រូពីបណ្តារោងចក្រកែច្នៃ ដើម្បីធ្វើតេស្តយថាប្រភេទកៅស៊ូចំនួន៦៥១ភាគសំណាក សម្រាប់ធ្វើការវាយតម្លៃសមត្ថភាព និងគុណភាពជ័រដែលបានកែច្នៃដោយបណ្តារោងចក្រទាំងនោះ
- ការរៀបចំរបាយការណ៍សរុបអំពីលទ្ធផលធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធក្នុងស្រុក (Laboratories Parallel Test) ចំនួន៤លើក គឺលើកទី៤៩, ៥០, ៥១ និងទី៥២ ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធមូលដ្ឋាន យោងតាមប្រកាសលេខ៤០៤ប្រក.កសក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការធ្វើតេស្តអន្តរមន្ទីរពិសោធជាមួយ IRA ចំនួន២លើក (លើកទី១១៦ និង១១៧) ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធយោងនៅក្នុងតំបន់ចំពោះប្រភេទកៅស៊ូ TSR
- ការត្រួតពិនិត្យតាមដាន និងវាយតម្លៃមន្ទីរពិសោធមូលដ្ឋាន ហើយនិងរោងចក្រកែច្នៃកៅស៊ូCSR របស់ក្រុមហ៊ុនស៊ីហ្វូរីសសស៍ (ខេមបូឌា) លីមីធីត (ចម្ការកៅស៊ូស្នួល) ចំនួន០២លើក ក្រុមហ៊ុនស៊ីហ្វូវ៉ាប់បើរ លីមីតធីត (ចម្ការកៅស៊ូឡាបានសៀក ខេត្តរតនគីរី) ចំនួន០១លើក និងរោងចក្រកែច្នៃកៅស៊ូស៊ីធីរ៉ាប់បើរ ខូ., អិលធីឌី ចំនួន០២លើក
- ការចូលរួមសហការជាមួយជំនាញការ និងក្រុមវាយតម្លៃគម្រោងអង្គការ UNIDO ដើម្បីវាយតម្លៃ អំពីលទ្ធផលការងារលើជំនួយបច្ចេកទេស និងឧបករណ៍ធ្វើតេស្តដល់មន្ទីរពិសោធន៍យថាប្រភេទ និងចុះពិនិត្យគម្រោងដែលបានជួយបណ្តុះបណ្តាលដល់កសិករកៅស៊ូគ្រួសារ និងក្រុមហ៊ុនចម្ការកៅស៊ូនៅខេត្តកំពង់ធំ កំពង់ចាម និងខេត្តត្បូងឃ្មុំ។

៤៧- ការបោះពុម្ពផ្សាយ៖

ឯកសារជាច្រើនប្រភេទត្រូវបានធ្វើការបោះពុម្ពផ្សាយ សំដៅផ្ទេរបច្ចេកវិទ្យានិងចែករំលែកព័ត៌មានដល់អ្នកបច្ចេកទេស អ្នកស្រាវជ្រាវ និយាយជារួមគឺប្រតិបត្តិករកៅស៊ូបានយល់ដឹងអំពីសកម្មភាពផ្សេងៗ ដែល វសកកបាននិងកំពុងអនុវត្ត។ ឯកសារដែលបានបោះពុម្ពផ្សាយ រួមមាន៖

- របាយការណ៍បច្ចេកទេសប្រចាំឆ្នាំ២០១៤-២០១៥
- ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស ឆ្នាំទី៨ ចំនួន០១លេខ
- ឯកសារចែកជូនក្នុងអង្គសិក្ខាសាលាអន្តរជាតិមាន ចំនួន២០០ច្បាប់
- ឯកសារចែកជូនប្រតិបត្តិករកៅស៊ូក្នុងវគ្គបណ្តុះបណ្តាលប្រចាំឆ្នាំ២០១៧ មានចំនួន ៤០០ច្បាប់។

## ២.៥ ការងារសហប្រតិបត្តិការអន្តរជាតិ

### ២.៥.១ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC)

៤៨- សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (Association of Natural Rubber Producing Countries: ANRPC) គឺជាអង្គការអន្តររដ្ឋាភិបាលដែលបានបង្កើតឡើងកាលពីឆ្នាំ១៩៧០។ សមាជិកភាពរបស់សមាគមត្រូវបានបើកទូលាយចំពោះរដ្ឋាភិបាលនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ។ គិតរហូតមកដល់ឆ្នាំ២០១៧ សមាគមនេះមានប្រទេសជាសមាជិកចំនួន១២ប្រទេស រួមមាន៖កម្ពុជា ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ប៉ាពួញូហ្គីណេ ភីលីពីន សិង្ហបុរី ស្រីលង្កា ថៃ វៀតណាម និងបង់ក្លាដេស។ **ទស្សនៈវិស័យ** របស់សមាគម គឺធ្វើ

ឱ្យឧស្សាហកម្មកៅស៊ូធម្មជាតិ មានចីរភាពប្រកបដោយលក្ខណៈសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ **បេសកកម្មរួម** គឺកែលម្អជាបន្តបន្ទាប់នូវផលិតភាពនៃកៅស៊ូគ្រួសារ កាត់បន្ថយចំណាយ បង្កើនតម្លៃបន្ថែម ផ្នែកលំហូរខាងក្រោម រកប្រភពប្រាក់ចំណូលបន្ថែម ប្រើប្រាស់លទ្ធភាព និងបទពិសោធន៍កៅស៊ូធម្មជាតិ សម្រាប់ជួយបរិស្ថាន និងបង្កើនសុខុមាលភាពរបស់កសិករកៅស៊ូគ្រួសារ។

៤៩- សកម្មភាពរបស់អគ្គនាយកដ្ឋានកៅស៊ូនៅក្នុងសមាគម ឆ្នាំ២០១៧កន្លងមក គឺ៖ (១)ចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពី "ការស្រាវជ្រាវ និងការវិភាគទីផ្សារកៅស៊ូធម្មជាតិ(ANRPC)" នៅទីក្រុងគូឡាឡាំពួរ កាលពីថ្ងៃទី១៧-២០ ខែមេសា ឆ្នាំ២០១៧ (២)ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការស្រាវជ្រាវ និងវិភាគទីផ្សារកៅស៊ូធម្មជាតិ ដែលបានរៀបចំដោយសមាគម ANRPC ចាប់ពីថ្ងៃទី២៤-២៨ ខែមេសា ឆ្នាំ២០១៧ នៅទីក្រុងគូឡាឡាំពួរ នៃប្រទេសម៉ាឡេស៊ី (៣)ចូលរួមកិច្ចប្រជុំលើកទី៤ របស់ក្រុមជំនាញផ្នែកស្ថិរភាវូបនីយកម្មតម្លៃកៅស៊ូធម្មជាតិ នៃបណ្តាលប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) នៅប្រទេសថៃ កាលពីថ្ងៃទី២៣-២៥ ខែឧសភា ឆ្នាំ២០១៧ (៤)ចូលរួមសិក្ខាសាលាស្តីពី "ការផ្គត់ផ្គង់ តម្រូវការ និងការធ្វើម៉ូឌែលឧស្សាហកម្មកៅស៊ូធម្មជាតិ របស់សមាគម (ANRPC) " នៅប្រទេសហ្វីលីពីន កាលពីថ្ងៃទី១១-១៤ ខែកក្កដា ឆ្នាំ២០១៧ និង(៥)ចូលរួមសន្និសីទ សន្និបាត និងកិច្ចប្រជុំ ប្រចាំឆ្នាំលើកទី១០ របស់សមាគមនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ចាប់ពីថ្ងៃទី២៣-២៧ ខែតុលា ឆ្នាំ២០១៧។

តារាងទី៣ កម្មវិធីសន្និសីទ កិច្ចប្រជុំ និងសន្និបាតប្រចាំឆ្នាំ២០១៧ របស់ ANRPC

| កាលបរិច្ឆេទ | កិច្ចប្រជុំ |
|---|---|
| ២៣/១០/២០១៧ | សន្និសីទកៅស៊ូប្រចាំឆ្នាំលើកទី១០និងសន្និសីទសារព័ត៌មាន<br>(10th Annual Rubber Conference and Press conference) |
| ២៤/១០/២០១៧ | - ពិធីបើកសន្និបាតលើកទី៤០របស់សមាគម<br>(Opening the 40th Session Assembly)<br>- កិច្ចប្រជុំលើកទី៣រវាងផ្នែករដ្ឋនៃសមាគម និងផ្នែកឯកជន<br>3th ANRPC Public-Private Meet<br>- កិច្ចប្រជុំលើកទី១១របស់គណៈកម្មាធិការព័ត៌មាន និងស្ថិតិ<br>11th Information &Statistics Committee Meeting: (ISC) |
| ២៥/១០/២០១៧ | - កិច្ចប្រជុំលើកទី១១របស់គណៈកម្មាធិការព័ត៌មាននិងស្ថិតិ (បន្ត)<br>11th Meeting of ISC (Continuation) |
| | - កិច្ចប្រជុំលើកទី១១របស់គណៈកម្មាធិការបញ្ហាឧស្សាហកម្ម<br>11th Industry Matters Committee Meeting: IMC |
| ២៦/១០/២០១៧ | - កិច្ចប្រជុំលើកទី១១របស់គណៈកម្មាធិការបញ្ហាឧស្សាហកម្ម (បន្ត)<br>11th Meeting of IMC (Continuation) |
| | - កិច្ចប្រជុំលើកទី៤៧របស់គណៈកម្មាធិការប្រតិបត្តិរបស់សមាគម<br>47th Executive Committee Meeting (Exco) |
| ២៧/១០/២០១៧ | - កិច្ចប្រជុំលើកទី៤៧របស់គណៈកម្មាធិការប្រតិបត្តិរបស់សមាគម (បន្ត)<br>47th Meeting of Exco (Continuation) |
| | ពិធីបិទសន្និបាតលើកទី៤០របស់សមាគម<br>Closing of 40th Session Assembly |

៥០- ក្នុងឆ្នាំ២០១៨នេះ ប្រទេសជាសមាជិក ANRPC នឹងចូលរួមកិច្ចប្រជុំ តាមកាលបរិច្ឆេទដូចខាងក្រោម៖

តារាងទី៤ ព្រឹត្តិការណ៍សំខាន់របស់ ANRPC ក្នុងឆ្នាំ២០១៨

| ល.រ | ព្រឹត្តិការណ៍ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|
| ១ | Second International Training in Rubber Market Analysis and Research (R-MART 2018) | ខែកុម្ភៈ ឆ្នាំ២០១៨ | ប្រទេសម៉ាឡេស៊ី |
| ២ | Seminar on Economics of Rubberized Roads and their Potential to Generate Additional Demand for NR | ខែមីនា ឆ្នាំ២០១៨ | ប្រទេសថៃ |
| ៣ | Fifth meeting of Expert Group on NR Price | ខែមេសា ឆ្នាំ ២០១៨ | ប្រទេសឥណ្ឌូនេស៊ី |
| ៤ | Workshop on “Towards Supply-Chain Efficiency” | ខែមិថុនា ឆ្នាំ ២០១៨ | ប្រទេសថៃ |
| ៥ | Workshop on Supply, Demand and Modeling of Work Rubber Industry | ខែកក្កដា ឆ្នាំ ២០១៨ | ប្រទេសហ្វីលីពីន |
| ៦ | 41st Session of Assembly, 11th Annual Rubber Conference and Annual Meetings | ខែតុលា ឆ្នាំ២០១៨ | ប្រទេសថៃ |
| ៧ | International Training in Estimation and Forecasting | ខែធ្នូ ឆ្នាំ២០១៨ | ប្រទេសម៉ាឡេស៊ី |

### ២.៥.២ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB)

៥១- សិក្ខាសាលាអន្តរជាតិ IRRDB-Workshop ស្តីអំពី "ការផ្ទេរបច្ចេកវិទ្យាដល់ផលិតករកៅស៊ូ និងកៅស៊ូគ្រួសារ" ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១២-១៣ ខែកក្កដា ឆ្នាំ២០១៧ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ ដោយមានភ្ញៀវពីបណ្តាសមាជិក IRRDB ចំនួន០៩ប្រទេសគឺ៖ កម្ពុជា ចិន ថៃ បារាំង ម៉ាឡេស៊ី ស្រីលង្កា ហ្វីលីពីន វៀត-ណាម និងអូស្ត្រាលី អញ្ជើញចូលរួមសរុបចំនួន១៦៩នាក់។

៥២ បានបញ្ជូនមន្ត្រីជំនាញទៅចូលរួមសិក្ខាសាលាអន្តរជាតិ សន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ នៅប្រទេសថៃចំនួន០១លើក នៅប្រទេសឥណ្ឌូនេស៊ីចំនួន០១លើក និងនៅប្រទេសម៉ាឡេស៊ីចំនួន០១លើក ហើយនិងចូលរួមវគ្គបណ្តុះបណ្តាលខ្លីនៅប្រទេសស្រីលង្កា។

### ២.៥.៣ កិច្ចសហប្រតិបត្តិការជាមួយ CIRAD

៥៣- ក្នុងការពង្រឹងនិងបង្កើននូវប្រសិទ្ធិភាពសិក្សានិងស្រាវជ្រាវអំពីបច្ចេកទេស និងវិទ្យាសាស្ត្រដំណាំកៅស៊ូ វសកក បានធ្វើសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្មសម្រាប់ការ អភិវឌ្ឍ (CIRAD) នៃប្រទេសបារាំង ដោយបានចុះអនុស្សរណៈនៃការយោគយល់គ្នាមួយកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦នៅវសកក។ នៅខែធ្នូ ឆ្នាំ២០១៧ជំនាញការ CIRAD បានបំពេញបេសកកម្មចំនួន១ដងនៅកម្ពុជា ដើម្បីរៀបចំអនុសាសន៍ក្លូនកៅស៊ូនៅប្រទេសកម្ពុជាសម្រាប់ឆ្នាំ ២០១៨-២០២០ ដោយបើកជាសិក្ខាសាលាមួយនៅស្ថានីយអនុវត្ត កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ។

### ២.៥.៤ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)

៥៤- ឆ្នាំ២០១៧ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) សហការជាមួយអគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តនូវគម្រោងចំនួន០២រួមមាន៖

- បន្តអនុវត្តគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជាមានសកម្មភាពដូចខាងក្រោម៖
  - ➢ ផ្តល់ថវិកាដល់ម្ចាស់ច្បារពូជក្នុងការថែទាំច្បារពូជរបស់ខ្លួនចំនួន១៨ច្បារពូជ លើ០៨ខេត្ត និងបានផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជកៅស៊ូរបស់កសិករចំនួន១០ច្បារពូជក្នុងចំណោមច្បារពូជទាំង១៨ច្បារពូជ លើ០៥ខេត្ត
  - ➢ ការបង្កើតច្បារពូជសមុច្ច័យ និងច្បារពូជយោង ចំនួនផ្ទៃដី០,៧ហិកតានៅស្ថានីយ៍អនុវត្តរបស់វិទ្យា-ស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
  - ➢ បានផ្ញើសំណាកស្លឹកកៅស៊ូទៅCIRAD សរុបបានចំនួន៣លើក សរុបបានចំនួន១.០៣០សំណាករបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
  - ➢ ចុះស្រង់ទិន្នន័យទិន្នផលជ័រកៅស៊ូរបស់កសិករកៅស៊ូគ្រួសារលើខេត្តចំនួន១០(ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ព្រះវិហារ បាត់ដំបង និងប៉ៃលិន)
  - ➢ ចុះយកសំណាកជ័រកៅស៊ូ(TSR)នៅតាមបណ្តារោងចក្រចំនួន៣៦រោងចក្រ ដើម្បីវិភាគគុណភាពជ័រ
- បានបញ្ចប់ការសិក្សាលទ្ធភាពដែលអាចធ្វើបានដំណាក់ការទី២ នៃគម្រោងអភិវឌ្ឍន៍កៅស៊ូគ្រួសារនៅកម្ពុជា នៅខេត្តគោលដៅចំនួន០២ គឺរតនគិរី និងបាត់ដំបង ដែលចុះសិក្សាដោយក្រុមហ៊ុន GLG Consultant។

### ២.៥.៥ កិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន

៥៥- អគ្គនាយកដ្ឋានកៅស៊ូបានលើកសំណើគម្រោងចំនួន៥៖ (១)គម្រោងពង្រឹងកិច្ចដំណើរការរបស់ការិយាល័យកៅស៊ូខេត្ត នៅ១៩ខេត្ត (២)គម្រោងគ្រប់គ្រងចម្ការកៅស៊ូគ្រួសារតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ GIS នៅ១៩ខេត្ត (៣)គម្រោងបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកៅស៊ូ (៤)គម្រោងទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ក្នុងវិស័យកៅស៊ូ និង(៥)គម្រោងជំនួយឧបត្ថម្ភគាំទ្រហិរញ្ញប្បទាន ហើយបានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈលិខិតលេខ១០៩៤ អក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១៧។ បន្ទាប់មកទៀត បានបញ្ជូនមន្ត្រីជំនាញ០២រូប ឲ្យទៅចូលរួមវគ្គសិក្ខាសាលា ស្តីពី ការគ្រប់គ្រង និងការអភិរក្សផ្នែកកេរ្តិ៍តំណែលកសិកម្មសម្រាប់បណ្តាប្រទេសតាមមាគ៌ានិងខ្សែក្រវ៉ាត់ក្នុងឆ្នាំ២០១៧ (Management and Conservation of Agriculture Heritage Site for Countries along the Belt and Road in 2017) ចាប់ពីថ្ងៃទី៧-២៧ ខែមិថុនា ឆ្នាំ២០១៧ នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន និងស្តីពីការដាំដុះកៅស៊ូដែលមានទិន្នផលខ្ពស់ (Rubber Cultivation with High Yield) នៅខេត្ត Hainan និងខេត្ត Quangxi នៃសាធារណរដ្ឋប្រជាមានិតចិន រយៈពេល១ខែ គឺចាប់ពីថ្ងៃទី៣ ខែសីហា ដល់ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៧។

### ២.៥.៦ កិច្ចសហប្រតិបត្តិការជាមួយ CATAS

៥៦- កិច្ចសហប្រតិបត្តិការជាមួយ CATAS (Chinese Academy of Tropical Agricultural Sciences) ក្នុងទិសដៅបង្កើននូវសកម្មភាពស្រាវជ្រាវអំពីដំណាំកៅស៊ូ បានធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS) ដោយបានចុះអនុស្សរណៈនៃការយោគយល់នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣

នៅទីក្រុងកូឡុមបូ ប្រទេសស្រីលង្កា។ នៅក្នុងឆ្នាំ២០១៧នេះ ពុំទាន់មានការរីកចម្រើនគួរឱ្យកត់ សម្គាល់នៅឡើយទេ។

## ២.៥.៧ ការរៀបចំគម្រោងអភិវឌ្ឍន៍កៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ និង វៀតណាម (CLV-DTA)

៥៧- បានប្រជុំពិនិត្យនិងពិភាក្សាឡើងវិញលើឯកសារពាក់ព័ន្ធនឹងផែនការអភិវឌ្ឍន៍រួមគ្នានូវផែនការអភិវឌ្ឍឧស្សាហកម្មកៅស៊ូនៅតំបន់ត្រីកោណអភិវឌ្ឍន៍នៃប្រទេសទាំងបី កម្ពុជា ឡាវ និងវៀតណាម (CLV DTA) កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ នៅអគ្គនាយកដ្ឋានកៅស៊ូ ដើម្បីត្រៀមដាក់ជូនកិច្ចប្រជុំកំពូលលើកទី១០ ថ្នាក់នាយករដ្ឋមន្ត្រីនៃប្រទេសទាំងបី នៅប្រទេសវៀតណាម ឆ្នាំ២០១៨នេះ។

# ៣. បញ្ហាប្រឈម

៥៨- ការអនុវត្តក្នុងឆ្នាំ២០១៧ អគ្គនាយកដ្ឋានកៅស៊ូ បានជួបនូវបញ្ហាប្រឈម និងការលំបាកមួយចំនួនដូចខាងក្រោម៖

- ពុំទាន់មានច្បាប់ស្តីពីកៅស៊ូនិងខ្វះលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាមួយចំនួន
- កិច្ចសហការរវាងអាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ចតាមច្រកព្រំដែន និងអង្គភាពពាក់ព័ន្ធក្នុងការទប់ស្កាត់ការនាំចេញជ័រនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសពុំទាន់បានល្អ
- មិនមានភាពស្មោះត្រង់រវាងកសិករកៅស៊ូគ្រួសារ អ្នកប្រមូលទិញ និងក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម
- កិច្ចសហការពីម្ចាស់ចម្ការកៅស៊ូ រោងចក្រសិប្បកម្មមួយចំនួននៅមិនទាន់ល្អ ជាមួយអគ្គនាយកដ្ឋានកៅស៊ូ
- ការនាំចេញកៅស៊ូរបស់ក្រុមហ៊ុនមួយចំនួនមិនបានបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់កៅស៊ូយថាប្រភេទកម្ពុជា(CSR)
- កង្វះមធ្យោបាយដឹកជញ្ជូន និងធនធានមនុស្ស នៅអគ្គនាយកដ្ឋានកៅស៊ូ និងការិយាល័យកៅស៊ូតាមខេត្ត ព្រមទាំងសមត្ថភាពមន្ត្រីមួយចំនួននៅមានកម្រិត
- ការយល់ដឹងពីបច្ចេកវិទ្យាកៅស៊ូថ្មីៗ របស់ប្រតិបត្តិករកៅស៊ូនៅមានកម្រិត
- លទ្ធភាពនៃការប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធនឹងឧស្សាហកម្មកៅស៊ូធម្មជាតិដែលជាធាតុចូលដ៏សំខាន់ក្នុងការរៀបចំរបាយការណ៍ ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅតែជាបញ្ហាប្រឈមនៅឡើយ
- តម្លៃកៅស៊ូធម្មជាតិមាននិន្នាការឡើងតិចតួច
- កង្វះធនធានមនុស្សផ្នែកវិទ្យាសាស្ត្រស្រាវជ្រាវ
- កង្វះទីតាំង និងផ្ទៃដីសម្រាប់សាងសង់អនុស្ថានីយ៍ពិសោធន៍ នៅតាមតំបន់ដែលមានសក្តានុពលដំណាំកៅស៊ូ
- ពុំទាន់មានទីតាំងចម្ការកៅស៊ូបង្ហាញ។

# ៤. សំណូមពរ

៥៩- ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈម និងតម្រូវការចាំបាច់ ក្នុងការអភិវឌ្ឍកៅស៊ូ ឱ្យទទួលបានភាពជោគជ័យតាមគោលដៅនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកៅស៊ូធម្មជាតិ នៅកម្ពុជាឆ្នាំ២០១១ - ២០២០ នោះអគ្គនាយកដ្ឋាន

កៅស៊ូ សូមសំណូមពរមួយចំនួនជូនថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យលទ្ធភាពដោះស្រាយ ដូចខាងក្រោម៖

- ជំរុញការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា
- ជំរុញកិច្ចសហការរវាងអាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ចតាមច្រកព្រំដែន និងអង្គភាពពាក់ព័ន្ធក្នុងការទប់ស្កាត់ការនាំចេញជ័រនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស
- សូមឲ្យម្ចាស់រោងចក្រសិប្បកម្មបង្កើតស្ថាក់ការប្រមូលទិញជ័រកៅស៊ូឱ្យបានច្រើន ដែលនៅជិតចម្ការកៅស៊ូគ្រួសារ និងផ្តល់ភាពត្រឹមត្រូវក្នុងការថ្លឹង ការគណនារកបរិមាណជ័រស្ងួត(DRC) តាមរូបមន្តដែលអគ្គ-នាយកដ្ឋានកៅស៊ូបានដាក់ឱ្យអនុវត្ត និងការទូទាត់មានតម្លាភាព
- ជួយផ្តល់បន្ថែមនូវធនធានមនុស្ស សម្ភារប្រើប្រាស់ និងមធ្យោបាយធ្វើដំណើរឱ្យបានគ្រប់គ្រាន់
- ជួយអន្តរាគមន៍ និងផ្តល់ទីតាំងផ្ទៃដីសម្រាប់សង់អនុស្ថានីយ៍ពិសោធន៍នៅតាមតំបន់មានដំណាំកៅស៊ូ
- ផ្តល់ទីតាំង និងថវិកាសម្រាប់បង្កើតចម្ការកៅស៊ូបង្ហាញ
- ជួយអន្តរាគមន៍ ទៅក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម រោងចក្រ សិប្បកម្ម និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចវិនិយោគដាំដុះដំណាំកៅស៊ូទាំងអស់ ឱ្យសហការជាមួយនាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានកៅស៊ូ ដើម្បីឱ្យអគ្គនាយកដ្ឋានកៅស៊ូក្តាប់បាននូវស្ថិតិកៅស៊ូ សម្រាប់ធ្វើរបាយការណ៍ ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូ
- ជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាកៅស៊ូដល់ម្ចាស់ចម្ការកៅស៊ូ រោងចក្រ សិប្បកម្ម
- ជំរុញឱ្យក្រុមហ៊ុននាំចេញកៅស៊ូត្រូវបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់កៅស៊ូយថាប្រភេទកម្ពុជា(CSR)
- ផ្តល់នូវធនធានមនុស្ស និងត្រូវមុខជំនាញដល់វិសកក ដើម្បីឲ្យដំណើរការស្រាវជ្រាវមាននិរន្តរភាព។

## ៥. សន្និដ្ឋាន

៦០- លទ្ធផលសម្រេចបាននៅក្នុងឆ្នាំ២០១៧នេះ បង្ហាញឱ្យឃើញថា ទោះបីមានការលំបាក និងជួបប្រទះបញ្ហាប្រឈមយ៉ាងណាក៏ដោយ ឈរលើស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុងរវាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលបានខិតខំអស់ពីកម្លាំងកាយកម្លាំងចិត្ត និងដោយមានការចូលរួមពីគ្រប់ប្រតិបត្តិករកៅស៊ូគោលដៅសូចនាករគ្រប់អនុកម្មវិធី និងចង្កោមសកម្មភាពត្រូវបានអនុវត្តសម្រេចតាមផែនការដែលបានកំណត់។ ម្យ៉ាងទៀតលទ្ធផលទាំងនេះ មួយចំណែកធំគឺដោយសារការណែនាំពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិសេសពីសំណាក់ឯកឧត្តមរដ្ឋមន្ត្រី ដែលជានិច្ចកាលតែងបានផ្តល់នូវអនុសាសន៍ល្អៗ ដោយមានការគាំទ្រទាំងស្មារតី ថវិកា និងបញ្ញាញាណ ដើម្បីឱ្យការអនុវត្តទទួលបាននូវលទ្ធផលជាផ្លែផ្កា និងមានប្រសិទ្ធភាពខ្ពស់។

## ៦. ទិសដៅអនុវត្តការងារឆ្នាំ២០១៨

៦១- ដើម្បីសម្រេចបាននូវភារកិច្ចនានាក្នុងឆ្នាំ២០១៨ ស្របតាមយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ២០១១-២០២០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ និងដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ លើការលើកស្ទួយវិស័យកសិកម្ម ដើម្បីលើកកម្ពស់ផលិតភាពពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម អគ្គនាយកដ្ឋានកៅស៊ូមានអនុកម្មវិធីចំនួន៣ ចង្កោមសកម្មភាពចំនួន១២ និងមានទិសដៅដូចខាងក្រោម៖

- ជម្រុញផលិតកម្មដំណាំកៅស៊ូនៅឆ្នាំ២០១៨ ឱ្យកើនដល់ ២២២,៤០៣៣ន់តោន ក្នុងកំណើន១៥ %
- បង្កើនល្បឿនត្រួតពិនិត្យនិងកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងលិខិតគតិយុត្តពាក់ព័ន្ធនានា
- បន្តជំរុញកិច្ចសហការជាមួយអាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ចតាមច្រកព្រំដែន និងអាជ្ញាធរពាក់ព័ន្ធក្នុងការទប់ស្កាត់ការនាំចេញជ័រនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស និងទប់ស្កាត់ការបើកស្នាក់ការប្រមូលទិញកៅស៊ូគ្រួសារដែលគ្មានលិខិតអនុញ្ញាត។
- ជំរុញការពង្រីកផ្ទៃដីដំណាំកៅស៊ូរបស់ក្រុមហ៊ុនឯកជន និងកៅស៊ូគ្រួសារ ពិសេសចូលរួមពិនិត្យតាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច សង្គមកិច្ច និងវាយតម្លៃលទ្ធផលដែលសម្រេចបាន
- បន្តធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា២០១៦-២០២៥
- បន្តអនុវត្តនិងពិនិត្យតាមដានការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៨
- ខិតខំប្រមូលចំណូលឱ្យសម្រេចតាមគោលដៅ
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពីការដាំដុះ ថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចម្រៃ ការយកផល និងការកែច្នៃ
- បន្តសុំបង្កើតទីតាំងអនុស្ថានីយនិងមន្ទីរពិសោធន៍បន្ថែម និងបង្កើនសមត្ថភាពស្រាវជ្រាវ ផ្សព្វផ្សាយនិងបង្ហាញ
- រៀបចំសិក្សា និងលើកគម្រោងស្នើសុំបង្កើតចម្ការកៅស៊ូបង្ហាញ
- ការយកចិត្តទុកដាក់បន្តការងារស្រាវជ្រាវ
- បន្តចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- ជំរុញការចងក្រង និងពង្រឹងសហគមន៍កៅស៊ូគ្រួសារ
- ពង្រឹងការអនុវត្តលើការបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ(CSR)សម្រាប់ការនាំចេញកៅស៊ូកែច្នៃ និងវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ
- ការអនុវត្តកម្មវិធីផ្លាស់ប្តូរក្លូនពហុភាគីក្នុងរង្វង់ប្រទេសជាសមាជិកនៃ IRRDB
- ការបន្តចូលរួមសន្និសីទកិច្ចប្រជុំ និងសន្និបាតប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យា។
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានា លើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិជ្ជាវិទ្យាសាស្ត្រ ព័ត៌មានអំពីការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់កៅស៊ូ អំពីនិន្នាការនៃតម្លៃកៅស៊ូលើទីផ្សារក្នុង និងក្រៅប្រទេស
- ជម្រុញស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារទាំងអស់ ឲ្យមានច្បាប់អនុញ្ញាតត្រឹមត្រូវ
- ពង្រីកដៃគូសហប្រតិបត្តិការក្នុងការស្វែងរកថវិកា និងបច្ចេកទេស ដើម្បីគាំទ្រការអភិវឌ្ឍកៅស៊ូគ្រួសារ
- បន្តចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានា ក្នុងការបណ្តុះបណ្តាលធនធានមនុស្សខាងវិស័យកៅស៊ូ៕

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១**

## រចនាសម្ព័ន្ធអគ្គនាយកដ្ឋានកៅស៊ូ

(យោងអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨)



# លទ្ធផលនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធី

| ឈ្មោះ ចង្កោម សកម្មភាព | សូចនាករ | | | | មូលហេតុ |
|---|---|---|---|---|---|
| | ឈ្មោះ | គោលដៅ | សម្រេច | % | |
| អនុកម្មវិធីទី១.១១ | | | | | |
| ១.១១.១- ផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារនិងមន្ត្រីបង្គោល | កសិករគ្រួសារនិងមន្ត្រីបង្គោលទទួលបានបច្ចេកវិទ្យាដំណាំកៅស៊ូ | ៧០៥ | ៧៤៩ | ១០៦ | ទទួលបានការចាប់អារម្មណ៍ពីកសិករ |
| ១.១១.២- ចងក្រង និងពង្រឹងសហគមន៍កសិករកៅស៊ូ | ចំនួនដងនៃការចុះ | ១៩ | ១៩ | ១០០ | |
| ១.១១.៣- សិក្សាលក្ខណៈសម្បត្តិ ( Profile) ចម្ការកៅស៊ូ | ចំនួនសំណាកដែលត្រូវធ្វើការសម្ភាសន៍ | ១៨០ | ១៨០ | ១០០ | |
| ១.១១.៤- ចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ចំនួនខេត្តដែលចុះ | ៧ | ៧ | ១០០ | |
| អនុកម្មវិធីទី១.១២ | | | | | |
| ១.១២.១- បណ្តុះបណ្តាលនិងផ្សព្វផ្សាយអំពីទីផ្សារកៅស៊ូដល់សហគមន៍កៅស៊ូគ្រួសារឱ្យបង្កើតមជ្ឈមណ្ឌលលក់ដូរកៅស៊ូរួម | ចំនួនសិក្ខាកាម | ៣០០ | ៣០០ | ១០០ | |
| ១.១២.២- ផ្តល់ព័ត៌មានពីការផ្គត់ផ្គង់ តម្រូវការ និងតម្លៃកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ | ចំនួនព្រឹត្តិបត្រកៅស៊ូធម្មជាតិ | ២,១៦០ | ២,១៥៩ | ៩៩.៩៥ | |

| ឈ្មោះ ចង្កោម សកម្មភាព | សូចនាករ | | | | មូលហេតុ |
|---|---|---|---|---|---|
| | ឈ្មោះ | គោលដៅ | សម្រេច | % | |
| អនុកម្មវិធីទី១.១៣ | | | | | |
| ១.១៣.១- ផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករផលិតផលកៅស៊ូ | ចំនួនសិក្ខាកាម | ១២០ | ១២០ | ១០០ | |
| ១.១៣.២- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក (USS) ដល់សហគមន៍កៅស៊ូគ្រួសារ | ចំនួនសិក្ខាកាម | ៣០០ | ៣០១ | ១០០.៣ | |
| អនុកម្មវិធីទី១.១៤ | | | | | |
| ១.១៤.១- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូនិងលិខិតបទដ្ឋានក្រោមច្បាប់ | ចំនួនប្រជុំក្រុមការងារ | ២៨ | ២៨ | ១០០ | |
| ១.១៤.២- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធដល់ផ្នែកកៅស៊ូ | ចំនួនប្រតិបត្តិករកៅស៊ូ | ៤០០ | ៤០០ | ១០០ | |
| ១.១៤.៣- បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ | ចំនួនសិក្ខាកាម | ៣៥ | ៣៥ | ១០០ | |
| អនុកម្មវិធីទី១.១៥ | | | | | |
| ១.១៥.១- តាមដានវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព | ចំនួនសិក្ខាសាលាការពិនិត្យពីវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព | ១ | ១ | ១០០ | |

| ឈ្មោះ ចង្កោម សកម្មភាព | សូចនាករ | | | | មូលហេតុ |
|---|---|---|---|---|---|
| | ឈ្មោះ | គោលដៅ | សម្រេច | % | |
| ១.១៥.២- តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគដីសម្បទានសេដ្ឋកិច្ចលើវិស័យកៅស៊ូ | ចំនួនចុះតាមដាន | ១១ | ១១ | ១០០ | |
| ១.១៥.៣- គាំទ្រការសម្របសម្រួលការងារនិងរៀបចំប្រជុំបូកការងារ | ចំនួនប្រជុំបូកសរុបប្រចាំឆ្នាំ | ១ | ១ | ១០០ | |
| អនុកម្មវិធីទី១.១៦ | | | | | |
| ១.១៦.១- សិក្សាស្រាវជ្រាវក្នុងការបង្កាត់និងជម្រើសពូជគ្រប់គ្រងច្បារពូជ និងអភិវឌ្ឍក្លូនកៅស៊ូប្រកបដោយប្រសិទ្ធភាពនិងបន្សាំបម្រែបម្រួលអាកាសធាតុក្នុងលក្ខខណ្ឌប្រទេសកម្ពុជា | -ច្បារបង្កាត់ពូជថ្មី (ពូជ/វដ្ត) | ១៩ | ១៩ | ១០០ | |
| | -ពិសោធន៍ទ្រង់ទ្រាយធំ (ក្លូន) | ៥៣ | ៥៣ | ១០០ | |
| | -តាមដានចំការពិសោធន៍ (តំបន់) | ៥ | ៥ | ១០០ | |
| ១.១៦.២- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកទេសកសិកម្មល្អ ក្នុងការដាំដុះនិងថែទាំដំណាំកៅស៊ូទាំងមុននិងក្រោយការប្រមូលផល | -អនុសាសន៍ប្រើប្រាស់ជី (ហិកតា) | ១៤០ | ១៤០ | ១០០ | |
| | -អនុសាសន៍ប្រព័ន្ធស្រោចស្រព (ហិកតា) | ១២ | ១២ | ១០០ | |
| | -តាមដានចំការពិសោធន៍ (ហិកតា) | ២២០.៤ | ២២០.៤ | ១០០ | |

| ឈ្មោះ ចង្កោម សកម្មភាព | សូចនាករ | | | | មូលហេតុ |
|---|---|---|---|---|---|
| | ឈ្មោះ | គោលដៅ | សម្រេច | % | |
| ១.១៦.៣- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកទេសប្រមូលផលជ័រកៅស៊ូ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៃការលូតលាស់ក្នុងវដ្ត | -តាមដានប្រព័ន្ធមុខចៀរ (ចំការ/ឆ្នាំ) | ២ | ២ | ១០០ | |
| | -វិភាគសរីរៈទឹកជ័រ (ដង/ឆ្នាំ) | ២ | ២ | ១០០ | |
| ១.១៦.៤- ធ្វើតេស្តបញ្ជាក់គុណភាពកៅស៊ូអន្តរមន្ទីរពិសោធន៍ជាមួយ IRA បណ្តាមន្ទីរពិសោធន៍ក្នុងស្រុក និងចុះត្រួតពិនិត្យរោងចក្រ CSR និង Lab CSR | -ពិសោធន៍ជាមួយ IRA (ដង/ឆ្នាំ) | ២ | ២ | ១០០ | |
| | -ពិសោធន៍ក្នុងប្រទេស (ដង/ឆ្នាំ) | ៤ | ៤ | ១០០ | |
| | -ត្រួតពិនិត្យរោងចក្រ (ដង/ឆ្នាំ) | ២ | ២ | ១០០ | |
| ១.១៦.៥- ទទួលធ្វើសាវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យទទួលស្គាល់ជាផ្លូវការអន្តរជាតិ វិភាគទាន IRRDB និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ | ដំណើរការទូទៅរបស់វិទ្យាស្ថាន | | | ៨៩.៦ | |

## ឧបសម្ព័ន្ធទី៣

# គោលដៅនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៨

| បរិយាយ | សូចនាករ លទ្ធផលក្នុងឆ្នាំ | គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ | | |
|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | មូលហេតុនៃការប្រែប្រួល |
| **អនុកម្មវិធីទី១.៥៖ ជំរុញការអភិវឌ្ឍន៍កៅស៊ូធម្មជាតិ ប្រកបដោយ និរន្តរភាព** | (១)ផលិតផលកៅស៊ូកើនឡើង(ភាគរយ) | | (១) ១៥ | (១) ប្ដូរលេខកូដអនុកម្មវិធីពីទី១.១១ ទៅ១.៥ (២០១៨) |
| | (២)គុណភាពកៅស៊ូ(ភាគរយ) | | (២) ៧៨ | (២) ប្ដូរឯកតាទៅជាភាគរយ(២០១៨) |
| ១.៥.១- ផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ និងមន្ត្រីបង្គោល | ចំនួនកសិករចូលរួម | ៦៧០ | ៨១៥ | ប្ដូរមកពីចង្កោមសកម្មភាពទី១.១១.១ |
| | ចំនួមន្ត្រីបង្គោលចូលរួម | ៣៥ | ៣៥ | |
| ១- បណ្ដុះបណ្ដាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារ | ចំនួនកសិករកៅស៊ូគ្រួសារ (នាក់) | ២៧០ | ៣១៥ | |
| ២- ផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ | ចំនួនកសិករ (នាក់) | ៤០០ | ៥០០ | |
| ៣- សិក្ខាសាលាផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់មន្ត្រីបង្គោល | ចំនួនមន្ត្រីបង្គោល (នាក់) | ៣៥ | ៣៥ | |
| ១.៥.២- ចងក្រង និងពង្រឹងសហគមន៍កសិករកៅស៊ូគ្រួសារ | ចំនួនសហគមន៍បង្កើត | ៣ | ៣ | ប្ដូរមកពីចង្កោមសកម្មភាពទី១.១១.២ |
| | ចំនួនសហគមន៍ពង្រឹង | | ៧ | |
| ១.៥.៣- ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាលបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ | ចំនួនប្រតិបត្តិករកៅស៊ូទទួលបានការបណ្ដុះបណ្ដាលពីបច្ចេកទេសកែច្នៃ | ៤២០ | ៥០០ | ប្ដូរមកពីចង្កោមសកម្មភាពទី១.១៣.១ និង១.១៣.២ |
| ១.៥.៤- បណ្ដុះបណ្ដាលនិងផ្សព្វផ្សាយពីទីផ្សារកៅស៊ូ | ចំនួនសិក្ខាកាម (នាក់) | ៣០០ | ៣៥០ | ប្ដូរមកពីចង្កោមសកម្មភាពទី១.១២.១ និង ១.១២.២ |
| | ចំនួនព្រឹត្តិបត្រកៅស៊ូ (ច្បាប់) | ២.១៦០ | ២.១៦០ | |
| ១.១១.៣- សិក្សាលក្ខណៈសម្បត្តិ ( Profile) ចម្ការកៅស៊ូគ្រួសារ | ចំនួនសំណាកដែលត្រូវធ្វើការសម្ភាសន៍ | ១៨០ | | បញ្ចប់ |
| ១.១១.៤- ចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ចំនួនខេត្តដែលចុះ | ៧ | | ជ្រកក្នុងអនុកម្មកម្មវិធីទី១.៦.២ |

| បរិយាយ | សូចនាករលទ្ធផលគន្លងឆ្នាំ | គោលដៅសូចនាករលទ្ធផលគន្លងឆ្នាំ | | |
|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | មូលហេតុនៃការប្រែប្រួល |
| **អនុកម្មវិធីទី១.៦៖ ពង្រឹងការរៀបចំនិងការអនុវត្តផែនការវិស័យកៅស៊ូ** | (១)អត្រាថវិកាត្រូវបានអនុវត្ត (%) | ៩៤ | ៩៥ | ប្តូរមកពីអនុកម្មវិធីពីទី១.១៥ ទៅ១.៦ |
| | (២)ចំនួនប្រតិបត្តិករកៅស៊ូទទួលបានការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្ត(នាក់) | ៤០០ | ៤៥០ | |
| ១.៦.១- តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព | (១)ចំនួនសិក្ខាសាលាការពិត្យពីវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព | ១ | ១ | ប្តូរមកពីចង្កោមសកម្មភាពទី១.១៥.១ |
| | (២)ចំនួនចុះពិនិត្យតាមដាននិងវាយតម្លៃ | ៨ | ៨ | |
| ១- ចុះពិនិត្យតាមដានការអនុវត្តថវិកា | ចំនួនចុះពិនិត្យតាមដាននិងវាយតម្លៃ | ៨ | ៨ | |
| ២- សិក្ខាសាលាពិនិត្យឡើងវិញលើវឌ្ឍភាពថវិកាកម្មវិធី | ចំនួនសិក្ខាសាលា (លើក) | ១ | ១ | |
| ៣- ប្រជុំពិគ្រោះយោបល់ក្រុមអនុវត្តគម្រោង | ចំនួនប្រជុំ(លើក) | ៥ | ៥ | |
| ៤- សិក្ខាសាលាណែនាំស្តីពីការរៀបចំគម្រោងថវិកា | ចំនួនសិក្ខាសាលា (លើក) | ១ | ១ | |
| ៥- ប្រជុំចងក្រងផែនការ | ចំនួនប្រជុំ(លើក) | ១០ | ១០ | |
| ៦- សិក្ខាសាលាពិគ្រោះការធ្វើផែនការមេ | ចំនួនសិក្ខាសាលា (លើក) | | ១ | |
| ១.៦.២- តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើវិស័យកៅស៊ូ | (១)ចំនួនចុះតាមដានការអនុវត្តកម្មវិធីវិនិយោគសម្បទានដីសេដ្ឋកិច្ចលើវិស័យកៅស៊ូ | ១១ | ១១ | ប្តូរមកពីចង្កោមសកម្មភាពទី១.១៥.២ |
| | (២)ចំនួនសិក្ខាសាលា | ២ | ២ | |
| ១- ចុះពិនិត្យការអនុវត្តកម្មវិធីវិនិយោគ សម្បទានដីសេដ្ឋកិច្ចលើវិស័យកៅស៊ូ | ចំនួនចុះតាមដាន (លើក) | ១១ | ១១ | |
| ២- សិក្ខាសាលាផ្សព្វផ្សាយអំពីលទ្ធផលនិងវិធីសាស្ត្រធ្វើស្ថិតិអំពីការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិ | ចំនួនប្រជុំសិក្ខាសាលា (លើក) | ២ | ២ | |
| ១.៦.៣- គាំទ្រការសម្របសម្រួលការងារនិងរៀបចំប្រជុំបូកការងារ | ចំនួនប្រជុំបូកសរុបប្រចាំឆ្នាំ (លើក) | | | ប្តូរមកពីចង្កោមសកម្មភាពទី១.១៥.៣ |
| ១-រៀបចំសន្និបាតឬប្រជុំបូកសរុបប្រចាំឆ្នាំ | ចំនួនប្រជុំបូកសរុបប្រចាំឆ្នាំ (លើក) | ១ | ១ | |
| ១.៦.៤- ផ្សព្វប្រជុំរៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យកៅស៊ូ | ចំនួនប្រជុំក្រុមការងារ (លើក) | ២៨ | ២៨ | ប្តូរមកពីចង្កោមសកម្មភាពទី១.១៤.១និង១.១៤.២ |
| | ចំនួនប្រតិបត្តិករកៅស៊ូ (នាក់) | ៤០០ | ៤៥០ | |
| ១.៦.៥- បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ | ចំនួនសិក្ខាកាម (នាក់) | ៣៥ | ៤០ | ប្តូរមកពីចង្កោមសកម្មភាពទី១.១៤.៣ |

| បរិយាយ | សូចនាករ<br>លទ្ធផលក្នុងឆ្នាំ | គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ | | |
|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | មូលហេតុនៃការប្រែប្រួល |
| **អនុកម្មវិធីទី១.៧៖ លើកកម្ពស់គុណភាពពូជកៅស៊ូថ្មី និងប្រសិទ្ធិភាពគុណភាពផលិតផលកៅស៊ូកម្ពុជា** | អត្រា (%) នៃការត្រួតពិនិត្យនិងវាយតម្លៃច្បារពូជ | ២០% | ២០% | |
| | អត្រា (%) នៃការចុះត្រួតពិនិត្យ និងវាយតម្លៃរោងចក្រកៅស៊ូ | ២% | ២% | |
| ១.៧.១- ការអភិរក្សនិងអភិវឌ្ឍក្លូនកៅស៊ូ ហើយនិងការសិក្សាលើការអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូ ដើម្បីបង្កើនផលិតភាពកៅស៊ូ | -ច្បារបង្កាត់ពូជថ្មី (ពូជ/វដ្ត) | ១៩ | ១៩ | |
| | -ពិសោធន៍ទ្រង់ទ្រាយធំ (ក្លូន) | ៥៣ | ៥៣ | |
| | -តាមដានចំការពិសោធន៍ (តំបន់) | ៥ | ៥ | |
| | -អនុសាសន៍ប្រើប្រាស់ជី (ហិកតា) | ១៤០ | ១៤០ | |
| | -អនុសាសន៍បហរព័ន្ធស្រោចស្រព (ហិកតា) | ១២ | ១២ | |
| | -តាមដានចំការពិសោធន៍ (ហិកតា) | ២២០.៤ | ២២០.៤ | |
| ១.៧.២- ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូកម្ពុជាស្របទៅតាមនិយាមអន្តរជាតិ | -តាមដានប្រព័ន្ធមុខចៀរ (ចំការ/ឆ្នាំ) | ២ | ២ | |
| | -វិភាគសរីរៈទឹកជ័រ (ដង/ឆ្នាំ) | ២ | ២ | |
| | -ពិសោធន៍ជាមួយ IRA (ដង/ឆ្នាំ) | ២ | ២ | |
| | -ពិសោធន៍ក្នុងប្រទេស (ដង/ឆ្នាំ) | ៤ | ៤ | |
| | -ត្រួតពិនិត្យរោងចក្រ (ដង/ឆ្នាំ) | ២ | ២ | |
| ១.៧.៣- ទទួលធ្វើសាវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យទទួលស្គាល់ជាផ្លូវការអន្តរជាតិវិភាគទាន IRRDB និងចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ | ដំណើរការទូទៅរបស់វិទ្យាស្ថាន | | | |

ឧបសម្ព័ន្ធទី៤

## ស្ថិតិ ផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ ឆ្នាំ១៩៨០-២០១៧

| ឆ្នាំ | សរុបផ្ទៃដី (ហិកតា) | ផ្ទៃដីចៀរ (ហិកតា) | ផលិតផល (តោន) | ទិន្នផល (គ.ក្រ/ហ.ត/ឆ្នាំ) | នាំចេញ (តោន) | ទឹកប្រាក់នាំចេញ (ដុល្លារ) |
|---|---|---|---|---|---|---|
| 1980 | 5,000 | 5,000 | 1,300 | 260 | 1,454 | |
| 1981 | 8,800 | 8,800 | 4,000 | 455 | 2,616 | |
| 1982 | 11,800 | 11,800 | 7,000 | 593 | 8,000 | |
| 1983 | 14,546 | 14,546 | 9,000 | 619 | 10,021 | |
| 1984 | 19,506 | 19,506 | 13,388 | 686 | 13,307 | |
| 1985 | 26,300 | 26,300 | 17,645 | 671 | 16,421 | |
| 1986 | 35,779 | 35,779 | 24,497 | 685 | 23,280 | |
| 1987 | 40,000 | 40,000 | 24,917 | 623 | 26,335 | |
| 1988 | 41,500 | 41,500 | 31,380 | 756 | 29,968 | |
| 1989 | 46,789 | 46,789 | 33,645 | 719 | 33,727 | |
| 1990 | 51,160 | 51,122 | 34,700 | 679 | 25,563 | |
| 1991 | 51,670 | 51,570 | 35,000 | 679 | 24,807 | |
| 1992 | 50,835 | 50,709 | 28,364 | 559 | 26,645 | |
| 1993 | 43,545 | 43,334 | 22,345 | 516 | 20,990 | |
| 1994 | 42,817 | 42,576 | 30,585 | 718 | 30,742 | |
| 1995 | 45,048 | 44,523 | 35,427 | 796 | 34,413 | |
| 1996 | 45,538 | 44,400 | 43,891 | 989 | 41,607 | |
| 1997 | 44,466 | 43,499 | 43,503 | 1,000 | 44,799 | |
| 1998 | 42,625 | 41,464 | 41,398 | 998 | 39,966 | |
| 1999 | 38,413 | 37,358 | 44,043 | 1,179 | 43,221 | |
| 2000 | 53,722 | 42,698 | 42,007 | 984 | 40,066 | |
| 2001 | 51,458 | 37,680 | 38,562 | 1,023 | 35,672 | |
| 2002 | 55,582 | 36,773 | 32,384 | 881 | 36,774 | |
| 2003 | 53,527 | 33,696 | 32,382 | 961 | 32,764 | |
| 2004 | 54,209 | 31,590 | 33,770 | 1,069 | 33,558 | |
| 2005 | 60,406 | 30,402 | 29,464 | 969 | 29,950 | |
| 2006 | 69,994 | 32,390 | 32,077 | 990 | 31,184 | |
| 2007 | 82,059 | 30,491 | 32,975 | 1,081 | 33,121 | 60,482,808 |
| 2008 | 107,901 | 34,313 | 37,050 | 1,080 | 36,000 | 58,320,000 |
| 2009 | 127,723 | 34,135 | 37,380 | 1,095 | 36,500 | 65,963,868 |
| 2010 | 181,433 | 38,406 | 42,250 | 1,100 | 42,000 | 111,510,000 |
| 2011 | 213,104 | 45,163 | 51,339 | 1,137 | 44,969 | 192,288,956 |
| 2012 | 280,355 | 55,361 | 64,525 | 1,166 | 59,917 | 174,760,129 |
| 2013 | 328,771 | 78,493 | 85,244 | 1,086 | 86,052 | 189,408,732 |
| 2014 | 357,809 | 90,545 | 97,054 | 1,072 | 100,151 | 154,160,799 |
| 2015 | 388,955 | 111,232 | 126,861 | 1,141 | 128,047 | 154,001,151 |
| 2016 | 432,735 | 126,996 | 145,200 | 1,143 | 145,100 | 187,164,551 |
| 2017 | 436,339 | 170,230 | 193,286 | 1,135 | 188,832 | 299,394,841 |

**ឧបសម្ព័ន្ធទី៥**

## ស្ថានភាពការខារអាជីវកម្ម ផលិតកម្ម និងនីហរ័ណកម្មកៅស៊ូ ឆ្នាំ២០១៧

| បរិយាយ | | ផ្ទៃដីកៅស៊ូ (ហិកតា) | | | ផលិតផលកៅស៊ូស្ងួត (តោន) | | | នីហរ័ណកម្មកៅស៊ូស្ងួត | | តម្លៃលក់ | ទិន្នផល | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចៀរជ័រ | ថែទាំ | សរុប | ក្រុមហ៊ុន | គ្រួសារ | សរុប | បរិមាណ(T) | ថង្លៃ(USD) | មធ្យម($/T) | kg/ha/ឆ្នាំ | |
| ១.ចម្ការកៅស៊ូកសិ -ឧស្សាហកម្ម (ក+ខ) | | ***69,726*** | ***210,501*** | ***280,228*** | ***83,037*** | ***549*** | ***83,586*** | ***81,132*** | ***128,289,158*** | ***1,581*** | ***1,191*** | |
| ក. ចម្ការកៅស៊ូកសិ -ឧស្សាហកម្ម | | ***34,497*** | ***18,198*** | ***52,696*** | ***42,237*** | ***549*** | ***42,786*** | ***38,632*** | ***61,428,534*** | ***1,590*** | ***1,224*** | |
| 1 | ក្រុមហ៊ុន សុភក្តិនីកា អ៊ីនវេសមេនគ្រុប (ជុប-ទំរីង) | 11,127 | 3,132 | 14,259 | 17,648 | | 17,648 | 15,986 | 26,101,958 | 1,633 | 1,586 | |
| 2 | ក្រុមហ៊ុន អាន ម៉ាឌី គ្រុប (ពាមជាំង-រមាសហែក) | 1,882 | 1,242 | 3,124 | 1,445 | | 1,445 | 1,410 | 2,124,110 | 1,506 | 768 | |
| 3 | ក្រុមហ៊ុន ក្រែក (ខេមបូឌា) ខូ អិលធីឌី (ក្រែក) | 4,135 | 664 | 4,798 | 5,415 | | 5,415 | 5,252 | 8,139,500 | 1,550 | 1,310 | |
| 4 | ក្រុមហ៊ុន អាន ម៉ាឌី គ្រុប (ចម្ការអណ្តូង) | 3,328 | 2,597 | 5,925 | 2,883 | | 2,883 | 2,845 | 4,287,890 | 1,507 | 866 | |
| 5 | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ | 4,131 | 4,536 | 8,667 | 4,204 | | 4,204 | 3,782 | 6,245,237 | 1,652 | 1,018 | |
| 6 | ក្រុមហ៊ុន ឡុងស្រេងអ៊ីនធើណេសិនណល់(បឹងកេត | 4,402 | 1,537 | 5,939 | 4,886 | | 4,886 | 4,684 | 7,341,676 | 1,567 | 1,110 | |
| 7 | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | 974 | 1,161 | 2,135 | 1,535 | | 1,535 | 1,533 | 2,348,430 | 1,532 | 1,577 | |
| 8 | ក្រុមហ៊ុន ស៊ីហ្វ រីសសស៍ លីមីតធីត (ស្នួល) | 3,859 | 548 | 4,406 | 3,523 | | 3,523 | 2,244 | 3,591,586 | 1,601 | 913 | |
| 9 | ក្រុមហ៊ុន ស៊ីហ្វ រ៉ាប់ប៊ើរ លីមីតធីត (រតនគិរី) | 79 | 2,588 | 2,666 | 97 | 549 | 646 | 346 | 456,646 | 1,318 | 1,235 | |
| 10 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 583 | 194 | 777 | 600 | | 600 | 550 | 791,500 | 1,439 | 1,031 | |
| ខ-ចម្ការកៅស៊ូ សម្បទាន សេដ្ឋកិច្ច | | ***35,229*** | ***192,303*** | ***227,532*** | ***40,800*** | | ***40,800*** | ***42,500*** | ***66,860,624*** | ***1,573*** | ***1,158*** | |
| | ចំនួន១២៧ ក្រុមហ៊ុន | 35,229 | 192,303 | 227,532 | 40,800 | | 40,800 | 42,500 | 66,860,624 | 1,573 | 1,158 | |
| ២-ចម្ការកៅស៊ូ គ្រួសារ - ឯកជន | | ***100,504*** | ***55,608*** | ***156,112*** | | ***109,700*** | ***109,700*** | ***107,700*** | ***171,105,683*** | ***1,589*** | ***1,091*** | |
| | ចំនួន ២០ ខេត្ត | 100,504 | 55,608 | 156,112 | | 109,700 | 109,700 | 107,700 | 171,105,683 | 1,589 | 1,091 | |
| សរុប (១+២) | | ***170,230*** | ***266,109*** | ***436,340*** | ***83,037*** | ***110,249*** | ***193,286*** | ***188,832*** | ***299,394,841*** | ***1,586*** | ***1,135*** | |

**ឧបសម្ព័ន្ធទី៦**

# ស្ថិតិផ្ទៃដីដំណាំកៅស៊ូកម្ពុជាឆ្នាំ២០១៧

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដីសម្បទាន | ផ្ទៃដីកៅស៊ូ ( ហិកតា ) | | |
|---|---|---|---|---|---|---|
| | | | | ចៀរជ័រ | ថែទាំ | សរុប |
| I | **ចម្ការកៅស៊ូកសិឧស្សាហកម្ម** | | **739,766** | **69,726** | **210,502** | **280,228** |
| **ក-អតីតចម្ការកៅស៊ូរដ្ឋនិងឯកជនភាវូបនីយកម្ម** | | **ខេត្ត** | **61,501** | **34,497** | **18,198** | **52,696** |
| 1 | សុភក្តិនីកា អ៊ិនវេសមេន គ្រុប (ជុប) | ត្បូងឃ្មុំ | 13,832 | 8,498 | 2,725 | 11,223 |
| | សុភក្តិនីកា អ៊ិនវេសមេន គ្រុប (ទំរីង) | កំពង់ធំ | 3,573 | 2,629 | 407 | 3,036 |
| 2 | អាន ម៉ាឌី គ្រុប(ពាមជាំង) | ត្បូងឃ្មុំ | 3,947 | 1,882 | 1,242 | 3,124 |
| 3 | ក្រែក(ខេមបូឌា) ខូអិលធីឌី(ក្រែក) | ត្បូងឃ្មុំ | 5,116 | 4,135 | 664 | 4,798 |
| 4 | ចម្ការកៅស៊ូមេមត់ | ត្បូងឃ្មុំ | 9,051 | 4,131 | 4,536 | 8,667 |
| 5 | ចម្ការកៅស៊ូ តាប៉ាវ | ត្បូងឃ្មុំ | 3,244 | 974 | 1,161 | 2,135 |
| 6 | អាន ម៉ាឌី គ្រុប(ចម្ការអណ្តូង) | កំពង់ចាម | 6,956 | 3,327 | 2,597 | 5,924 |
| 7 | ឡុងស្រេងអ៊ិនធឺណេស៊ិនណល (បឹងកេត) | កំពង់ចាម | 6,353 | 4,402 | 1,537 | 5,939 |
| 8 | ស៊ីហ្វរីសសស៍លីមីធីត(ស្នួល) | ក្រចេះ | 4,807 | 3,859 | 548 | 4,406 |
| 9 | ស៊ីហ្វរ៉ាប់ប៊ើរលីមីធីត(ឡាបានសៀក) | រតនគីរី | 3,589 | 79 | 2,588 | 2,666 |
| 10 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ត្បូងឃ្មុំ | 1,033 | 583 | 194 | 777 |
| **ខ-ចម្ការកៅស៊ូលើសម្បទានដីសេដ្ឋកិច្ច** | | **ខេត្ត** | **678,264** | **35,229** | **192,303** | **227,532** |
| 1 | សំរោង រ៉ាប់ប័រ អ៊ិនដាសស្ទ្រីភីធីអ៊ី អិលធីឌី | ឧត្តរ.+សៀមរាប | 9,658 | 2,250 | 2,025 | 4,275 |
| 2 | តៃនិញ សៀមរាបអភិវឌ្ឍន៍កៅស៊ូ | ឧត្តរមានជ័យ | 4,161 | | 3,834 | 3,834 |
| 3 | បេសរ៉ូយ៉ាល់ (ខេ)ខូអិលធីឌី | ឧត្តរ+ព្រះវិហារ | 4,055 | | 3,500 | 3,500 |
| 4 | សុខ សំណាង ឌីវេឡុបមេន | ឧត្តរមានជ័យ | 1,865 | | 850 | 850 |
| 5 | ហួត ម៉េងរីតា ខូ អិលធីឌី | ឧត្តរមានជ័យ | 4,195 | | 1,360 | 1,360 |
| 6 | តារា រ៉ាប់ប៊ើរ (ខេមបូឌា) ខូ អិលធីឌី | ឧត្តរមានជ័យ | 7,700 | | 26 | 26 |
| 7 | ទីមរីង រ៉ាប់ប៊ើរ ខូ អិលធីឌី | ឧត្តរមានជ័យ | 7,750 | | 272 | 272 |
| សរុប | | | 39,384 | 2,250 | 11,867 | 14,117 |
| 8 | ខេន លីមីធីត | សៀមរាប | 2,499 | 620 | 1,171 | 1,791 |
| សរុប | | | 2,499 | 620 | 1,171 | 1,791 |
| 9 | សុភក្តិនីកា អ៊ីនវេសមេន អាក្រូអ៊ិនដាសស្ទ្រីផ្លេន ខូអិលធីឌី | ស្ទឹងត្រែង | 10,000 | 1,900 | 2,908 | 4,808 |
| 10 | សល សុភា ពាណិជ្ជ គ្រុប ខូអិលធីឌី | ស្ទឹងត្រែង | 9,917 | 1,950 | 2,520 | 4,470 |
| 11 | ភូម៉ាឌី អិនវេសមេន គ្រុប | ស្ទឹងត្រែង | 10,000 | 670 | 1,930 | 2,600 |
| 12 | ស៊ីវ ហ្គេច អិនវេសមេន | ស្ទឹងត្រែង | 10,000 | | 1,520 | 1,520 |
| 13 | Green Sea Agric.(MRT) | ស្ទឹងត្រែង | 6,250 | | 349 | 349 |
| សរុប | | | 46,167 | 4,520 | 9,227 | 13,747 |

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដីសម្បទាន | ផ្ទៃដីកៅស៊ូ ( ហិកតា ) | | |
|---|---|---|---|---|---|---|
| | | | | ចៀរជ័រ | ថែទាំ | សរុប |
| I | **ចម្ការកៅស៊ូកសិឧស្សាហកម្ម** | | **739,766** | **69,726** | **210,502** | **280,228** |
| 14 | តាន់បៀន កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ | កំពង់ធំ | 7,767 | 4,560 | 2,684 | 7,244 |
| 15 | គៀក វ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ | កំពង់ធំ | 8,694 | 2,691 | 4,973 | 7,664 |
| 16 | ប៉ាវ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ | កំពង់ធំ | 5,293 | 2,534 | 2,860 | 5,394 |
| 17 | ស៊ី អ ស៊ី ខេ អភិវឌ្ឍន៍កៅស៊ូ | កំពង់ធំ | 5,272 | 200 | 4,372 | 4,572 |
| 18 | ប៊ី អិន អេ (ខេម) | កំពង់ធំ | 7,500 | | 2,505 | 2,505 |
| 19 | ស៊ី ស៊ី វី ខូអិលធីឌី | កំពង់ធំ | 2,014 | 47 | 1,881 | 1,928 |
| 20 | ហ្គោល ហ្វ៉យសុន(ខេមបូឌា) អេ/ស៊ី | កំពង់ធំ | 3,237 | 400 | 2,674 | 3,074 |
| 21 | កុល វាសនា អិនវេសមេន ខូ អិលធីឌី | កំពង់ធំ | 9,863 | | 1,520 | 1,520 |
| 22 | ស៊ី អ ស៊ី ខេ ២ អភិវឌ្ឍន៍កៅស៊ូ | កំពង់ធំ+សៀមរាប | 9,235 | 3,100 | 5,136 | 8,236 |
| 23 | បៀន ហៀក អិនវេសមេន ខូ អិលធីឌី | កំពង់ធំ+ព្រះវិ.+សៀម | 9,480 | | 8,032 | 8,032 |
| 24 | កៅស៊ូមេកុង ខូ អិលធីឌី | កំពង់ធំ+ព្រះវិ. | 6,012 | | 5,714 | 5,714 |
| 25 | សាម ម៉េង អាហារ័ណ នីហារ័ណ | កំពង់ធំ | 225 | 195 | | 195 |
| 26 | រតនៈខេម អាហ្គ្រោ អ៊ិនដាស្ទ្រី អិលធីឌី | កំពង់ធំ | 900 | 840 | | 840 |
| 27 | ទ្រីភាព អ៊ីមផត អ៊ិចផត | កំពង់ធំ | 600 | 581 | | 581 |
| 28 | ហ្វាម៉រ អ៊ីនវេសមេន ខូអិលធីឌី | កំពង់ធំ | 938 | | 107 | 107 |
| 29 | ហ្គោដេន ហ្វាម៉ីង អ៊ីនវេសមេន ខូអិលធីឌី | កំពង់ធំ | 925 | | 0 | 0 |
| 30 | នុភាព សុភី អ៊ិនវេសមេន | កំពង់ធំ | 488 | | 0 | 0 |
| 31 | អាន សុភី ហ្វាម៉ីង (ខេមបូឌា) ខូអិលធីឌី | កំពង់ធំ | 967 | | 0 | 0 |
| 32 | ឫទ្ធិមុនី សំណាងលាភ ខូអិលធីឌី | កំពង់ធំ | 1,745 | | 1,659 | 1,659 |
| 33 | អានម៉ាឌី ខូ អិលធីឌី | កំពង់ធំ+ព្រះវិ. | 9,993 | | 2,100 | 2,100 |
| 34 | សលៈ សុភា ពាណិជ្ជ គ្រុប ខូអិលធីឌី | កំពង់ធំ | 2,995 | | 200 | 200 |
| 35 | សម្បត្តិផ្លែធីណឹម | កំពង់ធំ | 2,496 | 75 | 1,727 | 1,802 |
| 36 | ទេពី អាគ្រូ វិនិយោគ | កំពង់ធំ | 1,000 | | 850 | 850 |
| 37 | ប៉ោ ខូច អភិវឌ្ឍន៍ ខូអិលធីឌី | កំពង់ធំ+ព្រះវិ. | 350 | | 10 | 10 |
| | សរុប | | 97,990 | 15,223 | 49,005 | 64,228 |
| 38 | ភូរៀង ក្រចេះអភិវឌ្ឍន៍កៅស៊ូ( ២គំរោង) | ក្រចេះ | 7,349 | 160 | 5,307 | 5,467 |
| 39 | ដុងណាយ ក្រចេះអភិវឌ្ឍន៍កៅស៊ូ(២គំរោង) | ក្រចេះ | 6,524 | 2,526 | 3,629 | 6,155 |
| 40 | ដុងភូ ក្រចេះអភិវឌ្ឍន៍កៅស៊ូ (៣គំរោង) | ក្រចេះ | 6,185 | 2,206 | 4,185 | 6,391 |
| 41 | ដូវទីសាយហ្គន- ប៊ីញហ្វឿក (អេសប៊ីខេ) | ក្រចេះ | 6,436 | | 2,634 | 2,634 |
| 42 | ដូវទៀង ក្រចេះ រ៉ាប់ប៊ើរ ឌីវេឡុបមេន | ក្រចេះ | 6,592 | | 1,996 | 1,996 |
| 43 | ដូនទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន | ក្រចេះ | 7,972 | | 2,307 | 2,307 |
| 44 | ប៊ីញហ្វឿក ក្រចេះ រ៉ាប់ប៊ើរ ២ | ក្រចេះ | 4,940 | | 4,391 | 4,391 |
| 45 | អេហ្វ្រី អ៊ិបដាសស្ទ្រៀល គ្រុប ឌីវេឡុបមេន | ក្រចេះ | 7,000 | | 580 | 580 |
| 46 | ស៊ី អេច ភី ប៊ី ឌីវេឡុបមេន | ក្រចេះ | 8,686 | | 509 | 509 |

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដីសម្បទាន | ផ្ទៃដីកៅស៊ូ ( ហិកតា ) | | |
|---|---|---|---|---|---|---|
| | | | | ចៀរជ័រ | ថែទាំ | សរុប |
| I | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | 739,766 | 69,726 | 210,502 | 280,228 |
| 47 | ឈុន ហុង រ៉ាប់ប័រ បេតជ័រ | ក្រចេះ | 8,202 | | 3,084 | 3,084 |
| 48 | ច័ន្ទ សុភា អភិវឌ្ឍន៍ | ក្រចេះ | 5,088 | | 467 | 467 |
| 49 | គ្រុប & លែន ឌីវេឡុបមែន(ខេមបូឌា) | ក្រចេះ | 7,200 | | 425 | 425 |
| 50 | ញូ ឡាញ ខេម ភីធីវ៉ាយ អិលធីឌី | ក្រចេះ | 8,977 | | 863 | 863 |
| 51 | តុង មិន គ្រុប អ៊ិនជីនារីង | ក្រចេះ | 7,465 | | 1,135 | 1,135 |
| 52 | ហ៊ាវ៉ាយស្សិន អេហ្គ្រីខលឈ័រ  ឌីវេឡុបមេន | ក្រចេះ | 9,996 | | 1,803 | 1,803 |
| 53 | កាសូទីម | ក្រចេះ | 15,165 | | 885 | 885 |
| 54 | អេសធើន រ៉ាប់ប៊ើរ(ខេមបូឌា) | ក្រចេះ | 4,868 | | 4,275 | 4,275 |
| 55 | ហេង ហេង សម្បត្តិ ចម្ការកៅស៊ូ(ស្វាយជ្រះ) | ក្រចេះ | 994 | 160 | 559 | 719 |
| 56 | ហេង ហេង សម្បត្តិ ចម្ការកៅស៊ូ(ធ្នូ) | ក្រចេះ | 609 | | 497 | 497 |
| 57 | រតនៈស្ដោន ខេមបូឌា | ក្រចេះ | 479 | | 450 | 450 |
| 58 | ជី ភី អ៊ី | ក្រចេះ | 678 | 321 | 187 | 508 |
| 59 | ថេរវិនិយោគ | ក្រចេះ | 520 | 300 | 190 | 490 |
| 60 | ខេមបូ ហា យ៉ុង វិនិយោគ កសិ-ឧស្សាហកម្ម | ក្រចេះ | 701 | 250 | 230 | 480 |
| 61 | ស៊ុន គុយ ទី អ៊ីមផត&អ៊ិចផត | ក្រចេះ | 903 | | 280 | 280 |
| 62 | វៀតណាម កម្ពុជាEconomy Trade and Industry | ក្រចេះ | 5,059 | 40 | 3,804 | 3,844 |
| 63 | ត្រាចញៀម ហ៊ុហាន ដូវទី-ហ្វាតទ្រៀន ដាយណាម-កម្ពុជា | ក្រចេះ | 2,616 | | 1,501 | 1,501 |
| 64 | សុវណ្ណរាជសីហ៍ ខូអិលធីឌី | ក្រចេះ | 6,525 | | 1,890 | 1,890 |
| 65 | សុវណ្ណ វុទ្ធី ខូ អិលធីឌី | ក្រចេះ | 5,000 | | 1,192 | 1,192 |
| 66 | E-Investment (Cambodia) Ltd | ក្រចេះ | 6,450 | 60 | 1,940 | 2,000 |
| 67 | សំណាងអង្គរ ឌីវេឡុបមេន អិលធីឌី | ក្រចេះ | 1,225 | 250 | 626 | 876 |
| 68 | ចំការកៅស៊ូមេមត់ ខូ អិលធីឌី | ក្រចេះ | 9,855 | | 1,019 | 1,019 |
| 69 | សាយខុង កៅស៊ូ ឌុកឌុង ខូ អិលធីឌី | ក្រចេះ | 1,852 | 80 | 1,419 | 1,499 |
| 70 | មេហ្គាស្ដា ប្រូឌ្យូស&អ៊ីមផតអិចផត | ក្រចេះ | 8,000 | | | 0 |
| 71 | មេហ្គាស្ដា អ៊ិនវេសមែន&ហ្វរេសស្ទ្រី ឌីវេឡុបមេន | ក្រចេះ | 8,000 | | | 0 |
| 72 | ហ្វ្រេតអ៊ែសេត អេហ្គ្រីខលឈើរីលែ ឌីវេឡុបមេន | ក្រចេះ | 8,528 | | | 0 |
| 73 | ធី ធី វ៉ាយ | ក្រចេះ | 9,780 | | | 0 |
| 74 | ហ្វ្រិនអាយលែន អេហ្គ្រីខលឈើរីលែឌីវេឡុបមេន | ក្រចេះ | 9,583 | | 1,624 | 1,624 |
| 75 | អេស៊ីវើលដ៍ អេហ្គ្រីខលឈើរ៍ល ឌីវេឡុបមេន | ក្រចេះ | 10,000 | | 75 | 75 |
| 76 | ហ្វ្រេតវ៉ិនឌើ អេហ្គ្រីខលឈើរ៍ល ឌីវេឡុបមេន | ក្រចេះ | 9,231 | | 157 | 157 |
| | សរុប | | 235,232 | 6,354 | 56,112 | 62,466 |
| 77 | ដាក់ឡាក់ មណ្ឌលគិរី អភិវឌ្ឍន៍កៅស៊ូ | មណ្ឌលគិរី | 5,108 | 1,000 | 421 | 1,421 |
| 78 | គូរីដាម៉ា ខូអិលធីឌី | មណ្ឌលគិរី | 5,345 | | 3,217 | 3,217 |
| 79 | សេដ្ឋីកូលា | មណ្ឌលគិរី | 4,273 | 950 | 1,293 | 2,243 |

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដីសម្បទាន | ផ្ទៃដីកៅស៊ូ ( ហិកតា ) | | |
|---|---|---|---|---|---|---|
| | | | | ចៀរជ័រ | ថែទាំ | សរុប |
| I | **ចម្ការកៅស៊ូកសិឧស្សាហកម្ម** | | **739,766** | **69,726** | **210,502** | **280,228** |
| 80 | វ៉ាវ៉ាណាស៊ី | មណ្ឌលគិរី | 2,705 | 1,800 | | 1,800 |
| 81 | ឌី ធី ស៊ី គ្រុប  ខូអិលធីឌី | មណ្ឌលគិរី | 11,837 | | 145 | 145 |
| 82 | លែន &  ឌីវេឡុបមេន | មណ្ឌលគិរី | 7,000 | | 900 | 900 |
| 83 | ផេស៊ីហ្វិក ឡូធើសយ៉ាញ-ស្តុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,014 | | 2,417 | 2,417 |
| 84 | ផេស៊ីហ្វិក ភើលយ៉ាញ-ស្តុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,614 | | 2,540 | 2,540 |
| 85 | ផេស៊ីហ្វិក ប្រាយដ៏ញ-ស្តុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,773 | | 4,817 | 4,817 |
| 86 | ផេស៊ីហ្វិក ហ្វ្រេនយ៉ាញ-ស្តុក ខមភេនី លីមីធីត | មណ្ឌលគិរី | 9,656 | | 1,988 | 1,988 |
| 87 | យូនីហ្វ្រីន រីសសស៍ យូអិលធីឌី | មណ្ឌលគិរី | 8,000 | | 454 | 454 |
| 88 | ប៊ិញហ្វឿកក្រចេះរ៉ាប់បើ១ ខមភេនី លីមីធីត | មណ្ឌលគិរី | 4,291 | | 3,451 | 3,451 |
| 89 | វី ឡា ឌីវេឡុបមេន ខូ អិលធីឌី | មណ្ឌលគិរី | 780 | | 479 | 479 |
| 90 | ខេ ភីស អ៊ិនវេសមេន (ខេមបូឌា) ខូអិលធីឌី | មណ្ឌលគិរី | 500 | 80 | 52 | 132 |
| សរុប | | | 87,896 | 3,830 | 22,173 | 26,003 |
| 91 | ហ៊ង អាន ម៉ាង យ៉ាង ខេ អភិវឌ្ឍន៍កៅស៊ូ | រតនគិរី | 5,733 | 432 | 4,956 | 5,388 |
| 92 | ក្រុង ប៊ុក រតនគិរី អភិវឌ្ឍន៍កៅស៊ូ | រតនគិរី | 6,051 | 60 | 5,561 | 5,621 |
| 93 | ហេង ប្រាឌ័រ ខូ អិលធីឌី | រតនគិរី | 1,961 | 850 | 1,031 | 1,881 |
| 94 | គីរី អភិវឌ្ឍន៍ | រតនគិរី | 661 | | 635 | 635 |
| 95 | វ៉ាសនា អ៊ិនវេសមេន | រតនគិរី | 1,764 | | 1,542 | 1,542 |
| 96 | ស៊ី អ ឌី ខូអិលធីឌី | រតនគិរី | 3,284 | | 3,284 | 3,284 |
| 97 | ជា ច័ន្ទរិទ្ធ អភិវឌ្ឍន៍ | រតនគិរី | 914 | 50 | 519 | 569 |
| 98 | ៧ មករា ផារី (ហេងអភិវឌ្ឍន៍) | រតនគិរី | 8,655 | | 205 | 205 |
| 99 | ហ៊ង អាន អូរយ៉ាដាវ ខូ អិលធីឌី | រតនគិរី | 3,129 | | 3,082 | 3,082 |
| 100 | មិត្តភាពម៉ែន សារុន | រតនគិរី | 1,330 | | 835 | 835 |
| 101 | កៅស៊ូអេលែវ ប៊ីអឹម យ៉ាញស្តុក | រតនគិរី | 1,425 | | 1,284 | 1,284 |
| 102 | ហួលឡីអ៊ីខូអ៊ីនដាសស្ទៀល | រតនគិរី | 7,118 | | 200 | 200 |
| 103 | ឌីអឹមគ្រុប ខូអិលធីឌី | រតនគិរី | 749 | | 190 | 190 |
| 104 | ជាំងលី(អ៊ិនវេសមេន)ខីអិលធីឌី | រតនគិរី | 1,900 | | 400 | 400 |
| 105 | នុភាព សុភី អ៊ិនវេសមេន | រតនគិរី | 9,000 | | 490 | 490 |
| 106 | JING ZHON RI | រតនគិរី | 9,224 | | 200 | 200 |
| 107 | ម្កុដ ពេជ្រ អភិវឌ្ឍន៦ | រតនគិរី | 1,950 | | 950 | 950 |
| សរុប | | | 64,847 | 1,392 | 25,363 | 26,755 |
| 108 | សីលាដាម៉ិច ខូ., លីមីតធីត | ព្រះវិហារ | 9,000 | | 490 | 490 |
| 109 | ទ្រីភាព អ៊ីមផត អ៊ិចផត | ព្រះវិហារ | 9,916 | | 4,103 | 4,103 |
| 110 | សុវណ្ណភូមិ វិនិយោគ កសិ-ឧស្សាហកម្ម | ព្រះវិហារ | 9,913 | | 3,520 | 3,520 |
| 111 | ឬទ្ធី ក្រានីត (ខេមបូឌា) ខូអិលធីឌី | ព្រះវិហារ | 1,646 | | 1,498 | 1,498 |

| ល.រ | ប្រភេទចម្ការកៅស៊ូ | | ផ្ទៃដីសម្បទាន | ផ្ទៃដីកៅស៊ូ ( ហិកតា ) | | |
|---|---|---|---|---|---|---|
| | | | | ចៀរជ័រ | ថែទាំ | សរុប |
